# មេរៀនទី ៨ បទគម្ពីរៈ ការបើកបង្ហាញជាសំណេរ របស់ព្រះជាម្ចាស់

នៅក្នុងមេរៀនមុន យើងបានរៀនអំពីការពិតជាច្រើនអំពីនិស្ស័យរបស់ព្រះជាម្ចាស់ និស្ស័យមនុស្ស និងដើមកំណើត ព្រមទាំងនិស្ស័យរបស់អំពើបាប យើងបានរៀនអំពីពួកទេវតា និង សកម្មភាពរបស់ពួកគេ និង ផែនការរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសលោះ មនុស្សជាតិដែលបានធ្លាក់ចុះ។ អ្នកប្រាកដជាបានសំគាល់ឃើញហើយថា ប្រភពសំខាន់ៗសម្រាប់សេចក្តីបង្រៀនទាំងអស់នេះ គឺជាព្រះគម្ពីរ ដែលមានបទគម្ពីរដ៏វិសុទ្ធ។ ព្រះគម្ពីរ គឺជាការបើកសំដែងជាលក្ខណៈសំណេរ របស់ព្រះជាម្ចាស់ អំពីអង្គទ្រង់ និង ស្នាព្រះហស្តរបស់ទ្រង់។

នេះគឺជារឿងសមហេតុផលមួយ ក្នុងការជឿថា ព្រះជាម្ចាស់ដ៏ជាក្សត្រ ប្រកបដោយក្តីស្រឡាញ់ យុត្តិធម៌ និង មានភាពជាបុគ្គល ទ្រង់ពិតជាសព្វព្រះហឫទ័យបើកបង្ហាញអង្គទ្រង់ ទៅកាន់ភាវៈដែលចេះគិតពិចារណារបស់ទ្រង់ តាមរយៈការកត់ត្រាជាសំណេរនោះ។ ជាការអស្ចារ្យណាស់ ដែលយើងបានដឹងថា ទ្រង់បានជ្រើសរើសប្រើប្រាស់មនុស្សដែលចុះចូលជាមួយ បំណងព្រះហឫទ័យរបស់ទ្រង់ ធ្វើជាអ្នកនិពន្ធនៃបទគម្ពីរទាំងនោះ។ ជាការជម្រុញចិត្តមួយ ដែលយើងបានសិក្សាអំពីការពិតអំពីរបៀបដែលកំណត់ត្រាដែលសរសេរឡើងដោយមនុស្សជាង ៤០ នាក់ ក្នុងអំឡុងពេល ១៦០០ ឆ្នាំ គឺត្រូវបានរក្សាទុកដោយព្រះជាម្ចាស់ និង មានផ្ទុកនៅក្នុងព្រះគម្ពីររបស់យើងនេះ។

នៅពេលដែលយើងចាប់ផ្តើមសិក្សាជំពូកទី៣ យើងត្រូវពិចារណាអំពីការបើកសំដែងអំពីគោលបំណងនៃការប្រោសលោះរបស់ព្រះជាម្ចាស់ ដូចដែលបានកត់ត្រានៅក្នុងបទគម្ពីរ។ ទីពីរ យើងនឹងរំឭកអំពីភស្តុតាង ដែលបានផ្តល់ឲ្យយើងនូវការធានាអះអាងថា ព្រះគម្ពីរគឺពិតជាព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់មែន។ បន្ទាប់មកទៀត យើងនឹងសិក្សាអំពីក្រុមជំនុំ គម្រោងដែលព្រះជាម្ចាស់ប្រើប្រាស់ដើម្បីត្រាស់ហៅមនុស្សដែលមិនទាន់បានសង្គ្រោះ ឲ្យចូលមកឯទ្រង់ ដើម្បីបីបាច់ពួកគេនៅក្នុងជំនឿ និង ធ្វើឲ្យពួកគេបានក្លាយទៅជាសក្ខីភាពដ៏មានប្រសិទ្ធិភាព។ នៅក្នុងមេរៀនចុងក្រោយនៃមុខវិជ្ជានេះ យើងនឹងសិក្សាអំពីគោលដៅនៃការប្រោសលោះ ស្របពេលដែលយើងពិចារណាអំពីអនាគត។

## គម្រោងមេរៀន

ក. តម្រូវការការបើកសម្ដែងជាសំណេរ
ខ. ការបណ្ដាលចិត្តឲ្យតែងបទគម្ពីរ
គ. ភាពផ្ដាច់មុខនៃបទគម្ពីរ
ឃ. ការបកស្រាយបទគម្ពីរ
ង. អំណាចរបស់បទគម្ពីរ

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. បកស្រាយពីមូលហេតុ ដែលព្រះជាម្ចាស់ចាំបាច់ត្រូវ ប្រទានការបើកសម្ដែងអំពីអង្គទ្រង់ ជាសំណេរ។
២. កំណត់អត្ថន័យ និង រៀបរាប់អំពីភស្តុតាងនៃពាក្យថាការបណ្ដាលចិត្តឲ្យតែងបទគម្ពីរឡើង។
៣. ប្រាប់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់ភាពផ្ដាច់មុខនៃបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី ហើយពិភាក្សាអំពីបញ្ជីកណ្ឌគម្ពីរទាំងនោះ។
៤. ប្រាប់អំពីវិធីសាស្រ្តដែលត្រូវវិភាគវែកញែក និង បកប្រែបទគម្ពីរ។
៥. ប្រាប់ថាតើព្រះបន្ទូលរបស់ព្រះជាម្ចាស់គួរតែមានអំណាចនៅត្រង់កន្លែងណាក្នុងជីវិតរបស់យើង

## សកម្មភាពក្នុងការសិក្សា

១. សិក្សាមេរៀនដោយផ្អែកទៅតាម ក្បួនដែលបានផ្ដល់ជូននៅក្នុងមេរៀនទី១រួចមកហើយ។ ត្រូវតែប្រាកដថា អ្នកបានអានបទគម្ពីរយោងទាំងអស់ ដែលអ្នកបានឃើញ នៅក្នុងមេរៀន ហើយឆ្លើយរាល់សំណួរសិក្សាទាំងអស់យ៉ាងយកចិត្តទុកដាក់។
២. ស្វែងរកពាក្យថ្មីៗសម្រាប់អ្នក នៅក្នុងអក្ខរានុក្រមនូវពាក្យសំខាន់ណាមួយ ហើយសិក្សាអត្ថន័យរបស់ពាក្យនោះ។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

# ***ពាក្យសំខាន់***

| | | |
|---|---|---|
| សំណេរអវសាននៃលោកីយ៍ | គោលលទ្ធិ | ការបណ្ដាលចិត្ត |
| ដោយសិទ្ធិអំណាច | ការលើកឡើង | ទំនៀមទម្លាប់និយាយតគ្នា |
| សំណេរដើម | លិខិត | ដែលអាចទុកចិត្តបាន |
| បញ្ជីកណ្ឌគម្ពីរ | ភាពផ្ដាច់មុខ | ការបើកសម្ដែង |
| ការលាតត្រដាង | បំភ្លឺ | ធ្វើឲ្យមានសុពលភាព |
| ខុសឆ្គង | វិសមិតភាព | |

# ក. តម្រូវការការបើកសម្តែងជាសំណេរ

**វត្ថុបំណងទី១.** *បកស្រាយពីមូលហេតុ ដែលព្រះជាម្ចាស់ចាំបាច់ត្រូវ ប្រទានការបើកសំម្តែងអំពីអង្គទ្រង់ ជាសំណេរ។*

មនុស្សយើងភាគច្រើន មិនសូវជាចងចាំបានល្អនោះទេ។ ប្រសិនបើព្រះជាម្ចាស់ មកបង្ហាញអង្គទ្រង់នៅចំពោះមុខរបស់ខ្ញុំ ក្នុងពេលជាក់លាក់ណាមួយនៅក្នុងជីវិតរបស់ខ្ញុំ មិនយូរប៉ុន្មានខ្ញុំអាចនឹងមិនចាំច្បាស់ ចំពោះរឿងមួយចំនួននៅក្នុងការបើកសម្តែងរបស់ទ្រង់ជាក់ជាមិនខាន។ មិនយូរប៉ុន្មាន ការចងចាំរបស់ខ្ញុំ ទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនោះ នឹងត្រូវសាបរលាបទៅ។ ខ្ញុំប្រហែលជាអាចរំឭកឡើងវិញយ៉ាងស្រពិចស្រពិលនូវព័ត៌មានខ្លះអំពីការបើកសម្តែងរបស់ទ្រង់ ប៉ុន្តែខ្ញុំច្បាស់ណាស់ថា ព័ត៌មាននោះនឹងមិនច្បាស់លាស់ ហើយមិនអាចយកជាការបាននោះទេ។ ប្រសិនបើខ្ញុំរៀបរាប់សាឡើងវិញ នូវព័ត៌មានទាំងអស់ប្រាប់កូនភ្លាមៗ បន្ទាប់ពីការបើកសម្តែងនោះក៏ដោយ គាត់ច្បាស់ជាមិនអាចចងចាំរឿងគ្រប់យ៉ាងដែលខ្ញុំបាននិយាយប្រាប់នោះទេ។ ប្រសិនបើកូនរបស់ខ្ញុំ នឹងប្រាប់ព័ត៌មាននេះបន្តទៅកាន់កូនៗរបស់គេ ប៉ុន្មានឆ្នាំក្រោយមកទៀត ពេលវេលាដែលកន្លងទៅនោះ នឹងធ្វើឲ្យការចងចាំរបស់គេស្រអាប់ទៅ ហើយព្រមទាំងធ្វើឲ្យខុសសាច់រឿងនោះផងដែរ។ អ្នកឃើញហើយថា វិធីសាស្ត្រនៃការចែកចាយបន្តការបើកសម្តែងរបស់ព្រះជាម្ចាស់នេះ ពិតជាមិនអាចយកជាការបាននោះទេ។

*ទំនៀមទម្លាប់និយាយតគ្នា* របស់មនុស្ស រឿងទាំងប៉ុន្មានដែលប្រាប់តៗគ្នា ពីជំនាន់មួយទៅជំនាន់មួយ អាចនឹងផ្លាស់ប្តូរយ៉ាងខ្លាំង នៅពេលដែលពួកគេនិយាយប្រាប់គ្នាជាបន្តបន្ទាប់។ ដូច្នេះ ការនេះមិនមែនជាវិធីសាស្ត្រដែលអាចយកជាការបាន ដើម្បីរៀនអំពីព្រះជាម្ចាស់ និង បំណងព្រះហឫទ័យរបស់ទ្រង់នោះទេ។

ព្រះជាម្ចាស់ប្រកបដោយប្រាជ្ញាញាណ និង អស្ចារ្យរបស់យើង បង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង តាមរយៈការទំនុកបម្រុងរបស់ទ្រង់សម្រាប់យើង។ ទ្រង់បានប្រទានការផ្គត់ផ្គង់ទៅលើខាងឯរូបកាយរបស់យើង តាមរបៀបជាច្រើន ដូចជាតាមរយៈការបង្កើតដ៏អស្ចារ្យរបស់ទ្រង់ ឲ្យមានវដ្តទឹកដែលបំពេញបន្ថែម និង បន្សុទ្ធប្រភពទឹកនៅលើផែនដី។ ចំណែកឯវិធីរបស់ទ្រង់ក្នុងការបំពេញបន្ថែមអុកស៊ីសែននៅក្នុងបរិយាកាសវិញនោះ ក៏អស្ចារ្យខ្លាំងណាស់ដែរ។ នៅពេលដែលយើងដកដង្ហើម យើងបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត ស្របពេលជាមួយគ្នានោះ រុក្ខជាតិបញ្ចេញអុកស៊ីសែនទៅក្នុងខ្យល់វិញ។ យើងស្របយកឧស្ម័នអុកស៊ីសែន ដែលបានបញ្ចេញដោយរុក្ខជាតិ ហើយរុក្ខជាតិទាំងនេះស្របយកឧស្ម័នកាបូនឌីអុកស៊ីត ដែលវាយកទៅប្រើប្រាស់ដើម្បីផលិតអាហាររបស់វា។

ប្រសិនបើព្រះជាម្ចាស់បានផ្គត់ផ្គង់សម្រាប់ទិដ្ឋភាពរូបកាយរបស់យើងប្រកបដោយព្រះហឫទ័យទុកដាក់យ៉ាងនេះ ទ្រង់ក៏ប្រាកដជានឹងមិន រំពឹងឲ្យយើងដោះស្រាយបញ្ហាខាងឯវិញ្ញាណដោយគ្មានជំនួយមកពីទ្រង់នោះដែរ។ បើគ្មានការបើកសម្តែងពីព្រះជាម្ចាស់នោះទេ យើងនឹងមិនអាចសូម្បីតែដឹងអំពីស្ថានភាពដ៏គួរឲ្យអស់សង្ឃឹមរបស់យើង និង សេចក្តីត្រូវការជំនួយរបស់យើងនោះទេ។ ដើម្បីយល់ពីមូលហេតុដែលការបើកសម្តែងពីព្រះជាម្ចាស់មានភាពចាំបាច់ នោះយើងត្រូវដឹងថាពាក្យ *ការបើកសម្តែង* មានន័យយ៉ាងដូចម្តេចទាក់ទងនឹងព្រះជាម្ចាស់។ពាក្យនេះមានន័យថា ព្រះជាម្ចាស់ *បង្ហាញ* ឬ *លាតត្រដាង* ទៅ

កាន់មនុស្សលោកនូវអ្វីដែលពួកគេមិនអាចដឹងអំពីទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់។ សូមចងចាំនិយមន័យពាក្យនេះ ក៏ដូចជាពាក្យសំខាន់ដទៃទៀតដែលយើងនឹងលើកមកបង្ហាញនៅក្នុងមេរៀននេះ។

## លំហាត់អនុវត្តន៍

១ ចូរសរសេរនិយមន័យពាក្យ *ការបើកសម្តែង* ដែលទាក់ទងទៅនឹងព្រះជាម្ចាស់។ ចូរប្រើសៀវភៅកត់ត្រារបស់អ្នកសម្រាប់សរសេរចម្លើយ។

ដោយព្រះជាម្ចាស់ទ្រង់អស្ចារ្យ និង ប្រកបដោយសេចក្តីស្រឡាញ់ ហើយដោយសារតែយើងត្រូវការជំនួយយ៉ាងខ្លាំង ដើម្បីដោះស្រាយបញ្ហាអំពើបាបរបស់យើង យើងអាចរំពឹងចង់ឲ្យព្រះជាម្ចាស់ មានព្រះបន្ទូលយ៉ាងច្បាស់មកកាន់យើង ថាទ្រង់គឺជានរណា និង អ្វីដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ។ លើសពីនេះទៅទៀត វាគឺជារឿងដែលសមហេតុផលបំផុត ដែលយើងត្រូវធានាឲ្យបានថា ការបើកសម្តែងនេះ ទទួលបានការការពារ ដើម្បីឲ្យមនុស្សអាចទទួលបាននូវចំណេះដឹង ដោយគ្មានភាពខុសឆ្គងត្រូវចំណុចណាមួយសោះឡើយ។ ដូច្នេះ យើងអាចដឹងនៅក្នុងចិត្តយើងថា ព្រះជាម្ចាស់បានប្រទានការបើកសម្តែងរបស់ទ្រង់ ដោយរក្សាទុកក្នុងទម្រង់ជាសំណេរនោះ ព្រោះទ្រង់មានហេតុផលដ៏ល្អមួយ។

## លំហាត់អនុវត្តន៍

២ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) វាពិតជាចាំបាច់ណាស់ ដែលព្រះជាម្ចាស់ត្រូវប្រទានការបើកសម្តែងជាសំណេរអំពីអង្គទ្រង់នេះមក ដើម្បីឲ្យមនុស្សអាចដឹងពីអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ឃើញក្នុងគេ។

ខ) ទំនៀមទម្លាប់និយាយតគ្នា គឺជាវិធីមួយដែលគួរឲ្យទុកចិត្តបំផុតក្នុងការ ចែកចាយការបើកសម្តែងរបស់ព្រះជាម្ចាស់ពីជំនាន់មួយទៅជំនាន់មួយ។

គ) ទំនៀមទម្លាប់និយាយតគ្នា គឺត្រូវបានគេជ្រើសរើស ជំនួសឲ្យការកត់ត្រាជាសំណេរ ព្រោះការនេះអាចបន្តវិវត្តន៍ទៅមុខ និង ផ្លាស់ប្តូរឲ្យសមទៅនឹងតម្រូវការរបស់យើង។

ឃ) ការកត់ត្រាជាសំណេរ ផ្តល់ឲ្យយើងនូវខ្នាតគំរូជាក់លាក់មួយ ដែលរក្សាទុកបានយ៉ាងសុក្រឹតនូវអ្វីដែលបានកើតឡើង ដើម្បីឲ្យកុំយើងវង្វេង ឬ ភ្លេចនូវអ្វីដែលបានកើតឡើង។

# ខ. ការបណ្តាលចិត្តឲ្យតែងបទគម្ពីរ

## អត្ថន័យនៃ ពាក្យការបណ្តាលចិត្ត

**វត្ថុបំណងទី២.** *កំណត់អត្ថន័យ និង រៀបរាប់អំពីភស្តុតាងនៃពាក្យថាការបណ្តាលចិត្តឲ្យតែង បទគម្ពីរឡើង។*

យើងជឿថាបទគម្ពីរគឺជា ការបើកសម្តែងដែលមិនចេះខុស(ដែលគ្មានកំហុស) ត្រូវបានព្រះជាម្ចាស់បើកសម្តែងអំពីអង្គទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់ នៅក្នុងជីវិតរបស់មនុស្ស។ បទគម្ពីរទាំងនោះត្រូវបានសរសេរឡើងដោយមនុស្ស ក្រោមការ*បណ្តាលចិត្ត*មកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ បទគម្ពីរទាំងនោះគឺជាការសរសេរទំនាក់ទំនងរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ ដែលអាចរកឃើញបានតែនៅពេលដែលព្រះជាម្ចាស់បើកសម្តែង សេចក្តីទាំងនោះមកកាន់មនុស្សជាតិតែប៉ុណ្ណោះ។

ដោយពាក្យថា *បទគម្ពីរ* យើងចង់និយាយសំដៅទៅលើសំណេរ ដែលយើងបានស្គាល់ថា គម្ពីរសម្ព័ន្ធមេត្រីចាស់ និង គម្ពីរសម្ព័ន្ធមេត្រីថ្មី ឬ កណ្ឌគម្ពីរទាំង ៦៦ របស់ព្រះគម្ពីរនោះឯង។ (អ្នកខ្លះរាប់បញ្ចូលទាំង កណ្ឌគម្ពីរខុសឆ្គង ទៅក្នុងបញ្ជីកណ្ឌគម្ពីរ ដូច្នេះហើយគេទទួលស្គាល់សំណេរដ៏ពិសិដ្ឋ មួយទៀតដែលមានកណ្ឌច្រើនជាងនេះ)។

ដោយពាក្យថា *ការបណ្តាលចិត្ត* យើងចង់បានន័យថា កិច្ចការមួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលទ្រង់បានដឹកនាំ ឬ គ្រប់គ្រងលើអ្នកនិពន្ធនៃបទគម្ពីរ ក្នុងការជ្រើសរើសសាច់រឿងដែលត្រូវសរសេរបញ្ចូល និង ពាក្យដែលពួកគេបានសរសេរ។ វាគឺជាការប្រទានសិទ្ធិអំណាចដ៏ពិសេសមួយ សម្រាប់កិច្ចការដ៏ពិសេស។ ព្រះជាម្ចាស់បានដាក់ទៅក្នុងគំនិត និង ដួងចិត្តរបស់អ្នកសរសេរបទគម្ពីរ នូវអ្វីដែលទ្រង់សព្វព្រះទ័យឲ្យគេបង្ហាញ។ ពួកគេបានសរសេរបទគម្ពីរ ដោយស្ថិតនៅក្រោមការគ្រប់គ្រង និង ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានរក្សាពួកអ្នកនិពន្ធ មិនឲ្យពួកគេមានកំហុសឆ្គង និង ការលុបពាក្យគ្រប់បែបយ៉ាង នៅក្នុងការកត់ត្រាអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យពួកគេសរសេរនោះឡើយ។ ប៉ុន្តែ រឿងមួយដែលគួរឲ្យកត់សំគាល់ដែរនោះ គឺថា ព្រះជាម្ចាស់បានប្រើប្រាស់ បុគ្គលិកលក្ខណៈរបស់អ្នកនិពន្ធដែលជាមនុស្សនោះ នៅក្នុងការកត់ត្រា ការបើកសម្តែងរបស់ទ្រង់ដែរ។ របៀបសរសេរ ឬ ពាក្យនៅក្នុងកណ្ឌនីមួយៗ ដែលផ្ទុកនៅក្នុងបទគម្ពីរ គឺមាន<u>ឯកលក្ខណៈ</u> ទៅតាមអ្នកនិពន្ធ និង ទៅតាមលក្ខណសម្បត្តិជាមនុស្សរបស់គាត់។

អ្នកនិពន្ធដែលជាមនុស្សទាំងនេះ អាចនឹងមិនបានដឹងថា អ្វីដែលពួកគេបានសរសេរឡើងនោះ នឹងបានក្លាយទៅជាទិដ្ឋភាពមួយនៃកំណត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់។ ក៏ដូចគ្នាផងដែរ នៅពេលដែលមានការបណ្តាលចិត្ត ពួកគេបានសរសេរដោយការស្តាប់បង្គាប់ ហើយពួកគេមិនដែលសង្ស័យចំពោះ ពាក្យអ្វីដែលពួកគេប្រើនោះឡើយ។ ឧទាហរណ៍ ព្រះជាម្ចាស់សម្តែងមកកាន់លោកលូកា អំពីភាពចាំបាច់នៃការស្រាវជ្រាវ និង សើបអង្កេតរឿងរ៉ាវរបស់សាក្សី អំពីព្រះជន្មរបស់ព្រះយេស៊ូ ដើម្បីឲ្យលោកអាចនឹងសរសេរសាច់រឿងឡើងទៅតាមលំដាប់លំដោយ (គម្ពីរលូកា ១:១-៤) ។ លោកប៉ូលតែងតែបានសរសេរកណ្ឌគម្ពីរដែលឆ្លើយតបទៅនឹងសំណួររបស់ក្រុមជំនុំ ដើម្បីបង្រៀនដែលជាតម្រូវការចាំបាច់សម្រាប់ក្រុមជំនុំ និង ដើម្បីធ្វើការណែនាំទៅកាន់បុគ្គលណាម្នាក់ (គម្ពីរ១កូរិនថូស ១:១០-១៣; ៧:១ គម្ពីរកាឡា

ទី ១:៦-៧ គម្ពីរ១ធីម៉ូថេ ១:៣ គម្ពីរភីលីម៉ូន ១០) ។ ប៉ុន្តែអ្វីគ្រប់យ៉ាងដែលគាត់បានសរសេរឡើង គឺតាមរយៈការបណ្ដាលចិត្តពីព្រះវិញ្ញាណដ៏វិសុទ្ធ។

ធាតុផ្សំពីរយ៉ាងនៃបទគម្ពីរនៅកណ្ដាលគម្ពីរសម្ព័ន្ធមេត្រីថ្មី ផ្ដល់ឲ្យយើងនូវការយល់ដឹងដ៏មានតម្លៃអំពីប្រភេទនៃការបណ្ដាលចិត្តដែលអ្នកនិពន្ធទទួលបាន។ លោកប៉ូលមានប្រសាសន៍ថា៖ "គ្រប់អត្ថបទគម្ពីរសុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង" ។ នោះមានន័យថា អត្ថបទត្រូវបានបណ្ដាលចិត្តឲ្យសរសេរដោយព្រះជាម្ចាស់។ លោកពេត្រុសក៏បានមានប្រសាសន៍ដូចខាងក្រោមនេះ៖

> គ្មាននរណាម្នាក់អាចបកស្រាយពាក្យរបស់ព្យាការី ដែលមានចែងទុកមកក្នុងគម្ពីរ តាមគំនិតរបស់ខ្លួនបានឡើយ ដ្បិតព្រះបន្ទូលដែលព្យាការីបានថ្លែងទុកមកនោះ មិនមែនចេញពីបំណងចិត្តរបស់មនុស្សទេ គឺព្រះវិញ្ញាណដ៏វិសុទ្ធវិញឯណោះ ដែលជំរុញចិត្តលោកទាំងនោះអោយថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះជាម្ចាស់។ (គម្ពីរ២ពេត្រុស ១:២០-២១)។

សម្រាប់អ្នកនិពន្ធផ្ទាល់ ក៏តែងតែនិយាយអំពីបទពិសោធន៍ជាមួយការបណ្ដាលចិត្តរបស់ខ្លួនគាត់ ឬបទពិសោធន៍របស់អ្នកសរសេរបទគម្ពីរដទៃផ្សេងទៀតដែរ។ ពួកគាត់និយាយអំពីការនេះដោយប្រើពាក្យថា ៖ *ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកគេ។*

## *លំហាត់អនុវត្តន៍*

៣ ចូរបើកព្រះគម្ពីររកខគម្ពីរនៅខាងក្រោមនេះ ហើយប្រាប់ពីអ្វីដែលបទគម្ពីរនីមួយៗបានថ្លែងដែលបានបង្ហាញថាព្រះជាម្ចាស់បានមានព្រះបន្ទូលតាមរយៈអ្នកនិពន្ធដែលជាមនុស្ស។

ក) គម្ពីរនិក្ខមនំ ១៧:១៤

ខ) គម្ពីរនិក្ខមនំ ២៤:៤

គ) គម្ពីរអេសាយ ៤៣:១

ឃ) គម្ពីរយេរេមា ១១:១

ង) គម្ពីរអេម៉ុស ១:៣, ៦, ៩

ច) គម្ពីរ១កូរិនថូស១៤:៣៧

ឆ) គម្ពីរ២ពេត្រុស ៣:១៥-១៦

ដូច្នេះ យើងឃើញថាការបណ្ដាលចិត្តរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ មកលើអ្នកនិពន្ធជាមនុស្ស នៅក្នុងការសរសេរបទគម្ពីរនេះ គឺពិតជា*ការផ្ដល់សិទ្ធិអំណាចដ៏ពិសេសមួយ សម្រាប់កិច្ចការដ៏ជាក់លាក់។*

# *លំហាត់អនុវត្តន៍*

៤ ចូរជ្រើសរើសសេចក្តីបង្រ្គាប់ដែលត្រឹមត្រូវ សម្រាប់ប្រយោគនេះ ៖ *ការបណ្តាលចិត្តឲ្យតែងបទគម្ពីរ* សំដៅទៅលើ

ក) កិច្ចការដែលប្រកបដោយភាពច្នៃប្រឌិតគ្រប់បែបយ៉ាង ដែលផ្អែកទៅលើផ្ទៃរឿងរបស់ព្រះគម្ពីរ។

ខ) ការផ្តល់សិទ្ធិអំណាច ជាក់លាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់កិច្ចការដ៏ជាក់លាក់មួយ

គ) គ្រប់ទាំងគំនិត និង ទង្វើ ដែលបានកត់ត្រានៅក្នុងបទគម្ពីរ ថាត្រូវបានបណ្តាលចិត្តពីព្រះជាម្ចាស់។

ឃ) ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅលើមនុស្សដែលត្រូវបានជ្រើសតាំងឲ្យកត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់ ទាក់ទងនឹងអង្គទ្រង់ផ្ទាល់ ព្រមទាំងផែនការរបស់ទ្រង់ផងដែរ។

ង) រចនាបទ និង ពាក្យពេចន៍របស់អ្នកនិពន្ធបទគម្ពីរដែលជាមនុស្សលោក។

ច) ខ្លឹមសារ ទាំងអស់នៃបទគម្ពីរ រួមទាំងធាតុផ្សំដែលត្រូវបានជ្រើសរើសយកមកដាក់បញ្ចូល និង ពាក្យពេចន៍ដែលត្រូវបានជ្រើសរើស។

## ឥស្តុតាងនៃការបណ្តាលចិត្ត

ចូរយើងបែរទៅមើល ការសិក្សាមួយអំពីភស្តុតាងនៃការបណ្តាលចិត្ត។ យើងនឹងពិចារណាអំពីការទទួលរបស់ព្រះយេស៊ូចំពោះព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ ការបំពេញតាមបទទំនាយរបស់ព្រះគម្ពីរ និង ភាពរួបរួមគ្នានៃសាច់រឿងនៅក្នុងព្រះគម្ពីរ។

១. *ព្រះយេស៊ូបានសម្តែងក្តីគោរព និង ការទទួលស្គាល់ចំពោះព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។*

ព្រះយេស៊ូបានបង្ហាញព្រះទ័យរបស់ទ្រង់ ទៅលើគម្ពីរសម្ព័ន្ធមេត្រីចាស់ តាមរបៀបបីយ៉ាង។ ទីមួយ ទ្រង់បានអះអាងថា កណ្ឌគម្ពីរទាំងនោះនឹងនៅចិតថេរ ជារៀងរហូត (សូមមើលគម្ពីរម៉ាថាយ ៥:១៧-១៨ គម្ពីរលូកា ១០:២៦; ២១:២២ គម្ពីរយ៉ូហាន ១០:៣៥)។ ទីពីរ ទ្រង់បានមានព្រះបន្ទូលថា បទគម្ពីរទាំងនោះ ថ្លែងអំពីទ្រង់ (គម្ពីរម៉ាថាយ ២៦:២៤ គម្ពីរម៉ាកុស ៩:១២ គម្ពីរលូកា ១៨:៣១; ២៤:៤៤ គម្ពីរយ៉ូហាន ៥:៣៩)។ ទីបី ព្រះយេស៊ូបានបង្ហាញថា ទ្រង់បានទទួលស្គាល់សិទ្ធិអំណាចនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ ដោយធ្វើការដកស្រង់បទគម្ពីរទាំងនោះមកមានព្រះបន្ទូល (គម្ពីរម៉ាថាយ ៤:៤, ៧,១០;២១:១៣; ២៦:៣១)។

តើអ្នកបានកត់សំគាល់ទេថា ព្រះយេស៊ូមិនដែលសម្តែងគូសបញ្ជាក់ថាឃ្លាណាមួយ ឬ សេចក្តីបង្រៀនណាមួយនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មានកំហុស ឬ មិនស័ក្តិសមនោះទេ? ប្រាកដណាស់ ទ្រង់ក៏អាចនឹង មានព្រះបន្ទូលអំពីទិដ្ឋភាពណាមួយ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ថាគ្មានការបណ្តាលពីព្រះជាម្ចាស់នោះទេ។ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់បានសម្តែងការទទួលស្គាល់យ៉ាងពេញលេញ ចំពោះសំណេរដ៏ពិសិដ្ឋនេះ ដែលសាសន៍យូដាផ្ទាល់ក៏បានទទួលស្គាល់ថាបានទទួលការបណ្តាលចិត្តពីព្រះជាម្ចាស់ដែរ។

ការចុះចូល និង ការទទួលស្គាល់របស់ព្រះយេស៊ូ ចំពោះគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ការប្រើប្រាស់ព្រះគម្ពីរនោះដោយព្រះអង្គផ្ទាល់ គឺសុទ្ធតែជាភស្តុតាងយ៉ាងរឹងមាំ អំពីការបណ្ដាលចិត្តពីអធិធម្មជាតិនៃព្រះគម្ពីរនោះ។

២. *បទទំនាយនៃព្រះគម្ពីរត្រូវបានបំពេញ*

ព្រះគម្ពីរមិនមែនគ្រាន់តែជាសៀវភៅមួយក្បាល ដែលត្រូវបានសរសេរឡើងដោយអ្នកនិពន្ធដែលមានអំណោនទានប៉ុណ្ណោះទេ។ ការបំពេញទៅតាមការទាយទុកជាមុនរបស់ព្រះគម្ពីរជាមួយនឹងភាពសុក្រឹតពេញលក្ខណៈ បានចង្អុលទៅកាន់ការរួមចំណែករបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រឹត្តិការណ៍ទាំងនេះមិនអាចត្រូវបានទាយទុកមុនដោយការអះអាងរបស់មនុស្សដែលគ្រាន់តែមានសតិបញ្ញាប៉ុណ្ណោះទេ។ ប៉ុន្តែ មានព្រឹត្តិការណ៍ជាច្រើនក៏ត្រូវបំពេញយ៉ាងអស្ចារ្យ ហើយមិនយូរមិនឆាប់ លំនឹងមួយនឹងត្រូវបានបំពេញបរិបូរណ៌ផងដែរ។

*កន្លែងដែលព្រះយេស៊ូប្រសូត។* ភូមិដ៏តូចមួយ ដែលជាកន្លែងព្រះមេស្ស៊ីទ្រង់នឹងត្រូវប្រសូតនោះ ត្រូវបានញែកចេញជាពិសេសដោយព្យាការី មីកាតាំងពីប្រមាណ៧០០ឆ្នាំមុនពេលដែលព្រឹត្តិការណ៍នេះកើតឡើងទៅទៀត៖ " បេថ្លេហិមអេប្រាតាអើយ! ក្នុងចំណោមអំបូរទាំងប៉ុន្មាននៅស្រុកយូដា អ្នកតូចជាងគេមែន តែមេដឹកនាំដែលត្រូវគ្រប់គ្រងលើអ៊ីស្រាអែល ក្នុងនាមយើង នឹងកើតចេញមកពីអ្នក។ លោកនោះមានដើមកំណើត តាំងពីបុរាណកាលដ៏យូរលង់" (គម្ពីរមីកា ៥:២)។ សាកគិតទៅមើល រឿងទាំងនោះ គឺពិតជាបានកើតឡើងចំពោះលោកយ៉ូសែប និង នាងម៉ារី និង ចំពោះទីក្រុងនោះមែន។ បើប្រើទស្សនៈវិស័យរបស់មនុស្សសុទ្ធសាទធ្វើ មកគិត គេអាចនឹងនិយាយថា យ៉ូសែបនិង ម៉ារីស្ទើតែមិនអាចធ្វើរឿងនោះបាននោះទេ! ប៉ុន្តែមិនយូរប៉ុន្មាន បន្ទាប់ពីពួកគេបានទៅដល់ក្រុងនោះ ព្រះយេស៊ូបានប្រសូតមក។ ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រកបដោយសព្វញ្ញុតញាណ ទ្រង់បានជ្រាបថាស្ដេចដ៏វិសុទ្ធ នឹងមិនប្រសូតនៅក្រុងយេរូសាឡឹមឡើយប៉ុន្តែទ្រង់បែរជាប្រសូតនៅភូមិបេថ្លេហិមដ៏តូចមួយទៅវិញ។

*ការក្បត់នឹងព្រះយេស៊ូ។* ខ្ញុំពិតជាស្ញើចក្នុងចិត្តណាស់ ដែលការក្បត់នឹងព្រះយេស៊ូនេះ ត្រូវបានអ្នកនិពន្ធធ្វើការទាយទុកជាមុន តាំងពីជាង១០០០ឆ្នាំមុនពេលដែលព្រះយេស៊ូទ្រង់ប្រសូតទៅទៀត។ គ្មាននរណាអាចនឹងគិតដល់ទៅថា ព្រះដែលត្រូវបានចាត់តាំង ដែលមានមនុស្សច្រើនជំនាន់រំពឹងចង់ឃើញ ក៏ជាព្រះដែលនឹងនាំសេចក្ដីសង្គ្រោះមកដល់សាសន៍យូដា ជាព្រះដែលត្រូវបានចាត់ឲ្យមក ដោយព្រះជាម្ចាស់ដើម្បីធ្វើការគ្រងរាជ្យជារៀងរហូត អាចនឹងត្រូវមិត្តសម្លាញ់ និង ជាអ្នករួមការងារបានក្បត់ទ្រង់ទៅវិញ។ ប៉ុន្តែការនេះមានកត់ត្រាដើម្បីឲ្យមនុស្សគ្រប់ទាំងអស់បានអាន៖ "អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំជាអ្នកដែលទូលបង្គំបានទុកចិត្តហើយក៏បានបរិភោគបាយរបស់ទូលបង្គំផងនោះបានលើកកែងជើងទាស់នឹងទូលបង្គំដែរ" (គម្ពីរទំនុកតម្កើង ៤១:៩)។

*របៀបនៃការសុគតរបស់ទ្រង់។* ការទាយទីបីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ គឺបានបង្ហាញពីទម្រង់មួយក្នុងការធ្វើគុតព្រះដែលត្រូវបានជ្រើសរើស ដែលមិនទាន់មានគេប្រើនៅក្នុងជំនាន់ដែលស្ដេចដាវីតកំពុងសរសេរគម្ពីរទំនុកតម្កើងជំពូក២២នោះឡើយ។ សាសន៍យូដា នៅក្នុងជំនាន់ស្ដេចដាវីតបានគប់សម្លាប់ជន

ឧក្រិដ្ឋដែលបានកាត់ទោសឲ្យស្លាប់។ គម្ពីរទំនុកតម្កើងជំពូក២២ បានទាញអំពីវិធីប្រហារជីវិតខុសពីនេះ ៖ "ពួកគេចាក់ទម្លុះដៃជើងទូលបង្គំ។" (ខ១៦)។ ការនេះប្រហែលជាចម្លែកណាស់សម្រាប់សាសន៍យូដា ប៉ុន្តែវាស្របទៅនឹងរូបភាពនៃការឆ្កាងរបស់ពួករ៉ូម៉ាំង យ៉ាងឥតខ្ចោះ។

ទំនាយក៏បានផ្តល់នូវសេចក្តីលំអិតអំពីការឆ្កាងព្រះយេស៊ូផងដែរ។ អ្នកក៏ប្រហែលជាបានចងចាំថា ព្រះជាម្ចាស់បានប្រទាន សេចក្តីណែនាំជាពិសេស អំពីការរៀបចំមនុស្សរបស់ទ្រង់សម្រាប់ការចាកចេញពីស្រុកអេស៊ីប។ សត្វចៀមសម្រាប់ធ្វើបុណ្យរំលង ត្រូវបានគេសម្លាប់ដើម្បីយកឈាមរបស់វាទៅលាបនៅលើទ្វារ។ ចំណែកឯសាច់របស់វាវិញ ក៏ត្រូវរៀបចំជាពិសេស គឺត្រូវអាំងទាំងមូលព្រះជាម្ចាស់ប្រហែលជាមានមូលហេតុជាច្រើនសម្រាប់ការណែនាំនេះ ប៉ុន្តែអ្វីដែលគេបានដឹងច្បាស់នោះ គឺថា៖ *មិនត្រូវបំបាក់ឆ្អឹងរបស់វាឡើយ*។ ប្រសិនបើពួកគេចង់ស្ងោរសាច់នោះ គេត្រូវបំបាក់ឆ្អឹងនោះ ដើម្បីឲ្យបំណែកសាច់អាចធ្លាក់ចូលទៅក្នុងឆ្នាំងរបស់ពួកគេ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានជ្រាបថា សត្វចៀមសម្រាប់បុណ្យរំលងរបស់សាសន៍អ៊ីស្រាអែលគឺជាប្រភេទសត្វចៀម ដ៏ល្អឥតខ្ចោះសម្រាប់បុណ្យរំលង។ ដូច្នេះ មានពាក្យទំនាយតាំងពី១០០០ឆ្នាំមុនថ្ងៃប្រសូតរបស់ទ្រង់ ថ្លែងថា ទ្រង់ត្រូវគេវាយឲ្យមានរបួស ទ្រង់ត្រូវគេចាក់ទម្លុះ និងមួលបង្កាច់ ប៉ុន្តែ *គ្មានឆ្អឹងណាមួយត្រូវបាក់បែកឡើយ។*(ចូរប្រៀបធៀប គម្ពីរអេសាយ ៥២:១៣-១៥ និង ៥៣:១-១២ ជាមួយនឹងគម្ពីរទំនុកតម្កើង ៣៤:២០)។

## *លំហាត់អនុវត្តន៍*

៥ ចូរអានគម្ពីរយ៉ូហាន ១៩:៣១-៣៧ ហើយថ្លែងប្រាប់អំពីអ្វីដែលយើងដឹង អំពីបទទំនាយដែលយើងទើបតែនឹងបានពិភាក្សាគ្នាហើយ ដោយសរសេរចម្លើយដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

*ទំនាយដទៃផ្សេងទៀត*។ ទំនាយជាច្រើនផ្សេងទៀត បានកើតមានឡើងពិតៗ តាមរបៀបដែលគេមិនអាចបកស្រាយថាជារឿងចៃដន្យបាននោះទេ។ សូមមើលទៅកាន់ទំនាយជាច្រើន ដែលចាប់ផ្តើកើតមានឡើងនៅចំពោះមុខរបស់យើង ជាមួយនឹងការកើតជាថ្មីនៃសាសន៍អ៊ីស្រាអែល ទៅជាប្រទេសមួយ។ (សូមមើលគម្ពីរអេសាយ ៣៥:១-២ គម្ពីរអេសេគាល ៣៧ គម្ពីរសាការី ៨:៧-៨; ១០:៩) ។ មានការទំនាយជាច្រើននៅក្នុងគម្ពីរដានីយ៉ែល បានកើតមានឡើង ដែលមានអ្នកវិភាគសេរីបានខិតខំប្រឹង ថ្លែងថា ការនោះ គឺគ្រាន់តែជាកំណត់ត្រាប្រវត្តិសាស្ត្រតែប៉ុណ្ណោះ មិនមែនជាបទទំនាយនោះទេ។ ពួកគេធ្វើការនេះមិនបានសម្រេចនោះទេ។ អ្នកប្រាជ្ញសម័យថ្មី កំពុងបន្តរកឃើញភស្តុតាងថ្មីៗដែលប្រាប់ថា លោកដានីយ៉ែលគឺពិតជាបានរស់នៅក្នុងជំនាន់ការគ្រប់គ្រងរបស់ក្រុងបាប៊ីឡូន ហើយការបើកសម្តែងដែលលោកទទួលបានមកអំពីរឿងអនាគត ក៏ត្រូវបានកត់ត្រានៅក្នុងអំឡុងឆ្នាំនោះដែរ។

៣. *ព្រះគម្ពីរមានសាច់រឿងរួមមួយដ៏អស្ចារ្យ*

ទោះបីជាព្រះគម្ពីរត្រូវបានសរសេរឡើងដោយអ្នកនិពន្ធចំនួន៤០នាក់ នៅក្នុងអំឡុងពេលប្រមាណ ១៦០០ ឆ្នាំក៏ដោយ កណ្ឌគម្ពីរនៅតែបង្ហាញសាច់រឿងដ៏សំខាន់តែមួយ៖ *ព្រះជាម្ចាស់ប្រោសលោះមនុស្សលោកតាមរយៈការបូជាព្រះជន្មព្រះរាជបុត្ររបស់ព្រះអង្គ គឺព្រះយេស៊ូគ្រិស្ត*។ នៅក្នុងបទគម្ពីរ មានប្រព័ន្ធនៃសេចក្តីបង្រៀនតែមួយ ខ្នាតគំរូសីលធម៌តែមួយ ផែនការនៃការសង្គ្រោះតែមួយ និង ផែនការដ៏ពិសិដ្ឋ

មួយនៅក្នុងយុគ្គសម័យ។ ផ្ទុយពីការផ្ទុយចាកពីគ្នា និង សាច់រឿងច្របូកច្របល់ កណ្ឌគម្ពីរទាំងអស់មានតួនាទីដើម្បីបំពេញ និង បង្គ្រប់ឲ្យគ្នាទៅវិញទៅមកតាមរបៀបដ៏ចុះសម្រុងគ្នា។ ការប្រមូលផ្តុំអស្ចារ្យនៃការបើកសម្តែង ដែលបង្ហាញឲ្យឃើញជាបន្តបន្ទាប់ តាមភាគដ៏ភាពរំជើបរំជួល ដែលនាំទៅដល់ចំណុចចុងបញ្ចប់ដ៏រំភើប នៅក្នុងជ័យជំនះលើសាតាំងក្នុងគ្រាចុងក្រោយ។ កណ្ឌនៅក្នុងព្រះគម្ពីរដែលខុសគ្នា ដូចជានៅក្នុងគម្ពីរលេវីវិន័យ និង គម្ពីរយ៉ូហានបង្កើតបានជារឿងតែមួយ សាច់រឿងតែមួយ កិច្ចការតែមួយ។ ចំណែកឯកណ្ឌគម្ពីរដំណឹងល្អទាំងបួន ផ្តល់ឲ្យយើងនូវសេចក្តីលំអិតអំពីព្រះជន្មរបស់ព្រះគ្រិស្ត ហើយបានបំភ្លឺយ៉ាងច្បាស់ទៅលើជ្រុងផ្សេងៗគ្នានៃលក្ខណសម្បត្តិ របស់ ព័ន្ធកិច្ចរបស់ទ្រង់។ យ៉ាងណាមិញ កណ្ឌគម្ពីរទាំងនោះ គឺជាចំណែករួមមកតែមួយ។

## *លំហាត់អនុវត្តន៍*

៦ ដោយមិនបើកទៅមើល ចំណុចខាងលើ ចូរឆ្លើយនឹងសំណួរទាំងប៉ុន្មាននៅខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) ចូររៀបរាប់ភស្តុតាងបីយ៉ាង អំពីការជំរុញនៃបទគម្ពីរ។

ខ) តើព្រះយេស៊ូ បង្ហាញថាទ្រង់ទទួលស្គាល់សិទ្ធិអំណាចរបស់គម្ពីរសម្ព័ន្ធមេត្រីចាស់ តាមរបៀបណា?

គ) ចូរផ្តល់ឧទាហរណ៍មួយ អំពីបទទំនាយនៅក្នុងព្រះគម្ពីរ ដែលត្រូវបានបំពេញរួច។

ឃ) តើសាច់រឿងចម្បងមួយនៃព្រះគម្ពីរដែល កើតឡើងតាំងពីគម្ពីរលោកុប្បត្តិ ដល់គម្ពីរវិវរណៈ?

# គ. ភាពផ្តាច់មុខនៃបទគម្ពីរ

**វត្ថុបំណងទី៣.** *ប្រាប់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់ភាពផ្តាច់មុខនៃបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី ហើយពិភាក្សាអំពីបញ្ជីកណ្ឌគម្ពីរ។*

នៅពេលដែលយើង និយាយអំពី*ភាពផ្តាច់មុខ* នៃបទគម្ពីរ យើងចង់បានន័យថាព្រះគម្ពីរគឺជាសំណេរនៃការបើកសម្តែងយ៉ាង*គ្រប់លក្ខណៈ* របស់ព្រះជាម្ចាស់អំពីសេចក្តីពិតរបស់ទ្រង់។ យើងបានឃើញថាព្រះជាម្ចាស់បានប្រើប្រាស់អ្នកនិពន្ធដែលជាមនុស្សជាច្រើននាក់ ឲ្យកត់ត្រាការបើកសម្តែងរបស់ទ្រង់។ យើងក៏បានពិភាក្សាគ្នា អំពីវេលាដែលចូលរួមនៅក្នុងការសម្រេចបាន ការលាតត្រដាងអំពីព្រះជាម្ចាស់។ បន្ទាប់មកយើង បានប្រទះនឹងបញ្ហាសំខាន់ពីរយ៉ាង ៖ ១) តើការបើកសម្តែងនេះ សម្រេចបាននៅពេលណា? ២) តើការបើកសម្តែងអំពីព្រះជាម្ចាស់ នេះបានរួមមានអ្វីខ្លះ? ចូរឲ្យយើងបាន សិក្សាអំពីបញ្ហាទាំងនេះ។

# ការសម្រេចបាន ការបើកសម្តែងអំពីព្រះជាម្ចាស់

យើងបានពិចារណា អំពីឥរិយាបថរបស់ព្រះយេស៊ូទៅចំពោះគម្ពីរសម្ព័ន្ធមេត្រីចាស់ ទ្រង់បានបង្ហាញការទទួលរបស់ទ្រង់ ដោយការដកស្រង់យកបទគម្ពីរពីក្នុងគម្ពីរនោះជាច្រើនលើកច្រើនសា។ ទោះជាយ៉ាងណា នៅពេលជិតដល់ទីបញ្ចប់នៃព័ន្ធកិច្ចលើផែនដីរបស់ទ្រង់ ទ្រង់បានបង្ហាញថា ទ្រង់មានសេចក្តីពិតជាច្រើនផ្សេងទៀត ដើម្បីបង្ហាញទៅកាន់ពួកសាវ័ករបស់ទ្រង់។

"ខ្ញុំមានសេចក្តីឯទៀតៗជាច្រើន ដែលត្រូវនិយាយប្រាប់អ្នករាល់គ្នា តែអ្នករាល់គ្នាពុំអាចទទួលនៅពេលនេះបានទេ។ កាលណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្តីពិតគ្រប់ចំពូក ដ្បិតសេចក្តីផ្សេងៗដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីណាដែលទ្រង់ព្រះសណ្តាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់អោយអ្នករាល់គ្នាដឹង អំពីហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខផង។ ព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់ខ្ញុំ ព្រោះព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា។ អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មានសុទ្ធតែជារបស់ខ្ញុំទាំងអស់។ ហេតុនេះហើយបានជាខ្ញុំពោលថា ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំយកមកប្រាប់អ្នករាល់គ្នា"។ (គម្ពីរយ៉ូហាន ១៦:១២-១៥)

នៅក្នុងខគម្ពីរនេះ យើងឃើញថាសេចក្តីពិតបន្ថែមទៀត នឹងត្រូវបានបើកបង្ហាញដោយព្រះវិញ្ញាណដ៏វិសុទ្ធ សេចក្តីពិតនេះ អាចនឹងរាប់បញ្ចូល *ព្រឹត្តិការណ៍នាពេលអនាគត* ("ហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខ") *ការដឹកនាំ និង ការបំភ្លឺផ្លូវ* ("ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា" ) និង *សេចក្តីបង្រៀន* បន្ថែមទៀត ("អោយស្គាល់សេចក្តីពិតគ្រប់ចំពូក") ដែលចាំបាច់ក្នុងការរស់នៅក្នុងមាគ៌ាដែល *ផ្គាប់ព្រះទ័យរបស់ព្រះជាម្ចាស់* ("ព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់ខ្ញុំ")។

រួមជាមួយការមានព្រះបន្ទូលរបស់ព្រះយេស៊ូ មានរឿងសំខាន់ៗពីរយ៉ាង៖

១. ទ្រង់សន្យាថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងសម្រេចការបើកសម្តែង ដោយដឹកនាំអ្នកដើរតាមទ្រង់ឲ្យស្គាល់សេចក្តីពិតគ្រប់ចំពូក (ខ១៣) ។ ទ្រង់នឹងជួយឲ្យពួកគេបានយល់ និងយកសេចក្តីបង្រៀនរបស់ទ្រង់ទៅប្រត្តិបត្តិ។

២. ទ្រង់មានព្រះបន្ទូលសំដៅទៅការបើកសម្តែងក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី តាំងពីមុនពេលដែលគម្ពីរនេះត្រូវបានបើកសម្តែងទៅកាន់អ្នកនិពន្ធ និង ត្រូវបានកត់ត្រាទៅទៀត។ អ្នកអាចនិយាយបានថា ទ្រង់បាន*បញ្ជាក់សុពលភាព* នៃគម្ពីរនេះទុកជាមុន។ ការ*បញ្ជាក់សុពលភាព* គឺបានន័យថា ការប្រកាសទទួលស្គាល់ និង ផ្តល់សិទ្ធិអំណាចឲ្យ។ តាមរបៀបនេះកិច្ចការរបស់អ្នកនិពន្ធគម្ពីរដំណឹងល្អ កណ្ឌគម្ពីរកិច្ចការ កណ្ឌគម្ពីរលិខិត និង កណ្ឌគម្ពីរវិវរណៈ ក៏ត្រូវបានទាយទុកមុន ត្រូវបានបកស្រាយ និង ទទួលស្គាល់។

អ្នកនិពន្ធដូចជា លោកប៉ូលបង្ហាញថាអ្វីដែលពួកគេសរសេរគឺបានទទួលពីការបើកសម្តែង។ ការនិយាយអំពីបទពិសោធន៍របស់លោក នៅក្នុងគម្ពីរអេភេសូ ៣:១-១២ លោកសាវ័កប៉ូលនិយាយថា លោក និង សាវ័កដទៃទៀត និង ព្យាការី គឺសុទ្ធតែបានទទួលបានពីការបើកបង្ហាញរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតមិនធ្លាប់បានដឹងពីមុនមក។ លោកពេត្រុសក៏បានឃើញពីតម្លៃនៃអ្វី ដែលព្រះវិញ្ញាណដ៏វិសុទ្ធ

បានបង្ហាញ និង បានជំរុញឲ្យធ្វើការកត់ត្រាទុកផងដែរ (គម្ពីរ២ពេត្រុស ១:២០-២១)។ នៅក្នុងគម្ពីរ២ពេត្រុស៣:១៥-១៦ លោកបាននិយាយចាត់ទុក កំណត់ត្រាសេចក្ដីបង្រៀនពីគោលលទ្ធិ របស់លោកសាវ័កប៉ូលថាជា*បទគម្ពីរ*។

មកដល់ឆ្នាំ ៦៤ ឬ ៦៥ គ.ស រឿងរ៉ាវភាគច្រើននៅក្នុងគម្ពីរដំណឹងល្អ និង កណ្ឌគម្ពីរសំបុត្រត្រូវបានសរសេរ និង ចែកចាយជាបន្ដបន្ទាប់នៅក្នុងចំណោមក្រុមជំនុំ។ ប្រមាណ ២៥ ឬ ៣០ឆ្នាំក្រោយមក លោកសាវ័កយ៉ូហានបានទទួលនូវព្រះគម្ពីរវិវរណៈ។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានអនុញ្ញាតឲ្យសាវ័កយ៉ូហាន ទទួលការបើកសម្ដែងនេះ ហើយក្រោយមកទៀត ទ្រង់ហាក់បីដូចជាបានសម្រេចការបើកសម្ដែងដ៏ពិសិដ្ឋនេះ។ ឥឡូវនេះ បទគម្ពីរបានត្រូវសម្រេចយ៉ាងបរិបូរណ៍ហើយ យើងមិនត្រូវបានបន្ថែម ឬ ដកចេញអ្វីទៀតឡើយ។ ព្រះជាម្ចាស់បានបើកបង្ហាញបំណងព្រះហឫទ័យ និង គោលបំណងរបស់ទ្រង់ម្ដងបន្ដិចៗ ក្នុងអំឡុងពេលប្រមាណ ១៦០០ឆ្នាំ។ យើងមិនត្រូវបានអ្វីផ្សេងទៀតទេ។ ព្រះជាម្ចាស់បានមានព្រះបន្ទូល អំពីរឿងគ្រប់យ៉ាងដែលទ្រង់សព្វព្រះទ័យនឹងព្រះបន្ទូលមកកាន់យើងរាល់គ្នា ទាក់ទងនឹងអង្គទ្រង់ និង ផែនការរបស់ទ្រង់សម្រាប់យើង។

នេះបានន័យថា ការជំរុញជាពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានធ្វើឲ្យព្រះបន្ទូលជាទម្រង់សំណេររបស់ព្រះជាម្ចាស់ កើតចេញជារូបរាងឡើងនោះ គឺមិនអាចកើតមានចំពោះយើងបានទេ ក្នុងពេលបច្ចុប្បន្ននេះ។ ការនោះគឺត្រូវបានរក្សាទុកផ្ដាច់មុខសម្រាប់តែអ្នកនិពន្ធបទគម្ពីរតែប៉ុណ្ណោះ។ យើងអាចទទួលបានការជំរុញចិត្តពីព្រះជាម្ចាស់ ដើម្បីរួមចំណែកក្នុងការពង្រីកអាណាចក្ររបស់ព្រះជាម្ចាស់បាន ប៉ុន្ដែយើងមិនអាចរួមចំណែកក្នុងការបើកសម្ដែងជាសំណេររបស់ទ្រង់បាននោះឡើយ។ ក្រោយពីបានអានសិក្សា និង អនុវត្តតាមសេចក្ដីបង្រៀននៃបទគម្ពីរ យើងអាចនិយាយដោយប្រាកដក្នុងចិត្តថា ព្រះជាម្ចាស់ពិតជាបានមានព្រះបន្ទូល*យ៉ាងច្បាស់* និង *យ៉ាងខ្ជាប់ខ្ជួន* មកកាន់យើង។ ទ្រង់បានបង្ហាញ *យ៉ាងគ្រប់គ្រាន់* នូវអ្វីដែលទ្រង់បានសព្វព្រះហឫទ័យទាក់ទងជាមួយយើង។ មិនចាំបាច់ត្រូវការ ឬ គិតអ្វីផ្សេងទៀតនោះទេ។

ជារឿងសំខាន់ណាស់ ដែលយើងត្រូវដឹងថាព្រះជាម្ចាស់នៅតែបន្ដមានព្រះបន្ទូលមកកាន់ក្រុមជំនុំរបស់ទ្រង់ ក្នុងពេលបច្ចុប្បន្ននេះ។ តាមរយៈព្រះអំណោយទាននៃការធ្វើទំនាយ ព្រះវិញ្ញាណនៅតែបន្ដប្រកាសទៅកាន់អ្នកជឿអំពីព្រះតម្រិះរបស់ព្រះជាម្ចាស់។ ទោះជាយ៉ាងណា បើការទស្សន៍ទាយទាំងនោះពិតជានឹងទទួលយកបានមែន វាត្រូវតែស្របគ្នាជាមួយនឹងព្រះបន្ទូល អាចបំភ្លឺ អាចដាស់តឿន និង អាចកំសាន្ដចិត្តអ្នកជឿ (គម្ពីរ១កូរិនថូស ១៤:៣) ។ គ្មានការអ្វីដែលអាចជំនួស ឬក៏អាចទាស់នឹង ការបើកសម្ដែងដែលព្រះបានប្រទានមកនៅក្នុងយុគសម័យរបស់ពួកសាវ័ក ដែលជាទិសដៅទូទៅសម្រាប់ក្រុមជំនុំបានសោះឡើយ។

## លំហាត់អនុវត្តន៍

៧ យើងបានឃើញថា ព្រះយេស៊ូបានបញ្ជាក់ថាពិតនូវបទគម្ពីរសម្ព័ន្ធមេត្រីចាស់ តាមយៈការលើកយកបទគម្ពីរទាំងនោះមកប្រើជារឿយៗ នៅក្នុងព័ន្ធកិច្ចរបស់ទ្រង់។ ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ ដែលទាក់ទងនឹងបទគម្ពីរសម្ព័ន្ធមេត្រីថ្មី ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) តើបទគម្ពីរបង្ហាញអ្វីខ្លះ មកកាន់យើងដែលបញ្ជាក់ថាពិត ព្រះយេស៊ូទ្រង់បានដាក់ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីជាបទគម្ពីរ ជាមុន?

ខ) តើព្រះយេស៊ូបានប្រាប់យើងថាអ្វីខ្លះជាសេចក្ដីពិតបន្ថែមដែលត្រូវបើកបង្ហាញ ដែលអាចនឹងរាប់បញ្ចូលបាន?

គ) ចូរថ្លែងបទគម្ពីរពីរ ដែលបង្ហាញថាពួកសាវ័កផ្ទាល់ ក៏ដឹងថាអ្វីដែលពួកគេបាននឹងកំពុងតែសរសេរនោះ គឺជាការបើកសម្ដែងពីព្រះជាម្ចាស់។

៨ ហេតុអ្វីបាន វាជារឿងសំខាន់ដែលយើងត្រូវដឹងថា ការបើកសម្ដែងជាសំណេររបស់ព្រះជាម្ចាស់ដែលហៅថាព្រះគម្ពីរនោះ គឺជាការបើកសម្ដែងដែលពេញបរិបូរណ៌របស់ព្រះជាម្ចាស់? ចូរប្រើប្រាស់សៀវភៅកត់ត្រារបស់អ្នកសម្រាប់ឆ្លើយនឹងសំណួរនេះ។

## បញ្ជីកណ្ឌគម្ពីរ

ប្រមាណពី២០០០ឆ្នាំ បានកន្លងផុតទៅ តាំងពីការបើកសម្ដែងបទគម្ពីរចុងក្រោយ។ ការបើកសម្ដែងនោះ រួមមានការប្រោសលោះរបស់ព្រះជាម្ចាស់ ដូចដែលបានបង្ហាញនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ការអញ្ជើញចុងក្រោយរបស់ទ្រង់ ទៅកាន់មនុស្សលោក នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី។

អ្នកប្រហែលជាអាចសួរថា "តើកំណត់ត្រានៃសេចក្ដីពិតដែលបានបើកបង្ហាញជាច្រើន អាចត្រូវបានគេចងក្រងទៅជាសៀវភៅមួយក្បាលបានយ៉ាងដូចម្ដេច? តើគេបានធ្វើការចងក្រងនោះនៅពេលណា? តើមានស្ថាប័ន គ្រឹះស្ថាន ឬ បុគ្គលណាដែលមានទំនួលខុសត្រូវក្នុងការចងក្រងព្រះគម្ពីរឡើង?" យើងនឹងពិចារណាអំពីសំណួរទាំងនេះ?

## ការបង្កើតព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់

យើងចាត់ទុកកណ្ឌគម្ពីរទាំង៣៩នៃព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ថា ជា*បញ្ជីកណ្ឌគម្ពីរ* (canon) មួយ។ ពាក្យនេះគឺបានមកពីពាក្យក្រិក *ខានន(Kanon)* ដែលអត្ថន័យដើមគឺ "ម៉ែត្រវាស់ឬ បន្ទាត់"។ ក្រោយមកវាប្រែទៅជាមានន័យថា "បន្ទាត់វាស់ វិន័យ ឬខ្នាតគំរូមួយ"។ នៅពេលដែលយើងយកពាក្យនេះមកប្រើជាមួយនឹងបទគម្ពីរ ពាក្យថាបញ្ជីកណ្ឌគម្ពីរ (canon) នេះគឺសំដៅទៅលើកណ្ឌគម្ពីរដែលបានត្រូវបានវាស់វែងដោយផ្អែកលើលក្ខណវិនិច្ឆ័យជាក់លាក់មួយ និង ត្រូវបានគេឃើញថាមានលក្ខណៈពេញលេញស្របតាមសេចក្ដីកំណត់សម្រាប់ឲ្យកណ្ឌគម្ពីរនោះក្លាយជាការបើកសម្ដែងដែលបណ្ដាលឲ្យតែងរបស់ព្រះជាម្ចាស់។

ជាការសង្ខេបខ្លីៗ ទីចាប់ផ្ដើមនៃការបើកសម្ដែងរបស់ព្រះជាម្ចាស់ ត្រូវបានកត់ត្រាឡើងដោយលោកម៉ូសេ ប្រហែលជាក្នុងឆ្នាំ១៤៥០ មុនគ.ស។ ការលាតត្រដាងចុងក្រោយនៃគម្ពីរសម្ពន្ធមេត្រីចាស់ គឺត្រូវបានកត់ត្រានៅម្ដុំចុងសតវត្សទី៥ មុនគ.ស។ លោកម៉ូសេត្រូវបានគេជឿថាជាអ្នកនិពន្ធកណ្ឌគម្ពីរដំបូងទាំងប្រាំ នៃគម្ពីរសម្ពន្ធមេត្រីចាស់ ដែលគេតែងតែហៅថា គម្ពីរ*ក្រឹត្យវិន័យ*។ បន្ទាប់មកទៀត នៅក្នុងគម្ពីររបស់សាសន៍ហេប្រឺ មានគម្ពីរ*ព្យាការី*។ កណ្ឌគម្ពីរទាំងនេះរួមមាន កណ្ឌគម្ពីរដែលបានលាតត្រដាងទៅកាន់អ្នកដែលធ្វើការនៅក្នុងតំណែងជាព្យាការី។ ចំណែកទីបីនៃកណ្ឌគម្ពីរ ដែលគេហៅថា កណ្ឌគម្ពីរ*សំណេរ*រួមមានសំណេរបីក្រុម ៖ ១) កណ្ឌគម្ពីរដែលសរសេរឡើងសម្រាប់កម្មវិធីជាក់លាក់ ដូចជា ពិធីជប់លៀងជាដើម (ឧទាហរណ៍ កណ្ឌគម្ពីរនាងអេធើរ ត្រូវបានគេយកទៅអាននៅក្នុងកម្មវិធីជប់លៀង នៅបុណ្យពូរីម ២) កណ្ឌគម្ពីរកំណាព្យ (គម្ពីរទំនុកតម្កើង គម្ពីរសុភាសិត និង គម្ពីរយ៉ូប) និង ៣) កណ្ឌគម្ពីរប្រវត្តិសាស្ត្រដែលមិនមែនជាទំនាយ (គម្ពីរដានីយ៉ែល គម្ពីរអេសរ៉ា គម្ពីរនេហេមា និង គម្ពីរបាក្សត្រ ដែលត្រូវបានសរសេរឡើងដោយអ្នកដែលមិនធ្វើការនៅក្នុងតំណែងជាព្យាការីនោះទេ ទោះជាយ៉ាងណា លោកដានីយ៉ែលបានប្រើប្រាស់ព្រះអំណោយទានជាព្យាការីរបស់លោក)។ កណ្ឌគម្ពីរដែលបង្កើតបានទៅជាព្រះគម្ពីររបស់សាសន៍ហេប្រឺ គឺដូចទៅនឹងកណ្ឌគម្ពីរទាំង៣៩ ដែលយើងបានស្គាល់នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ផងដែរ។

ភស្តុតាងបានមកពីអ្នកប្រវត្តិសាស្ត្រសាសន៍យូដា លោកយ៉ូសេហ្វឺស (ឆ្នាំ៩៥ គ.ស) បានបង្ហាញថាកណ្ឌគម្ពីរសម្ពន្ធមេត្រីចាស់ ត្រូវបានគេចងក្រងមកតែមួយ ដោយមានការដឹកនាំពីលោក អេសរ៉ា និង សមាជិកដទៃទៀតនៅក្នុងមហាសាលាប្រជុំ នៅក្នុងសតវត្សទីប្រាំ មុនជំនាន់ព្រះគ្រិស្តទៅទៀត។ កណ្ឌគម្ពីរទាំង៣៩ ដែលរួមទាំងបីក្រុមដែលយើងបានលើកយកមកនិយាយនៅខាងលើ មានគម្ពីរក្រឹត្យវិន័យ គម្ពីរព្យាការី និង គម្ពីរសំណេរ ដែលមនុស្សរបស់ព្រះជាម្ចាស់ប្រកាន់យកជាវិន័យរបស់ពួកគេ ដែលប្រទានមកពីព្រះជាម្ចាស់ និងជាវិន័យតែមួយរបស់ពួកគេ សម្រាប់ជំនឿ និង ទង្វើរបស់ពួកគេ។ កំណត់ត្រាអំពីការពិភាក្សា នៅក្នុងសាលាបង្រៀននៅក្នុងក្រុង ចាមនា (Jamnia) នៅស្រុកភីលីស្ទីន ចន្លោះឆ្នាំ ៧០ និង ឆ្នាំ១០០ គ.ស ក៏បានទទួលស្គាល់វត្តមានរបស់ បញ្ជីកណ្ឌគម្ពីរទាំង៣៩ ដែលយើងហៅថា គម្ពីរសម្ពន្ធមេត្រីចាស់នេះ។

## ការបង្កើតព្រះគម្ពីរសម្ពន្ធមេត្រីថ្មី

នៅក្នុងអំឡុងពេល ពីសតវត្សមុនជំនាន់ព្រះយេស៊ូ ជនជាតិអ៊ីស្រាអែលទទួលរងការគាប់សង្កត់ និងការប្រៀតប្រៀនដ៏ព្រៃផ្សៃ ពីជាតិសាសន៍ដទៃ។ ប្រជាជនបានឆ្ងល់ថា "ហេតុអ្វីបានជាព្រះជាម្ចាស់មិនលូកព្រះហស្តក្នុងរឿងនេះ? តើនឹងគ្មានសង្ឃឹម ថានឹងទទួលបានយុត្តិធម៌ទេឬអី?

ប្រៀបបានទៅនឹងការឆ្លើយតបទៅនឹងការចោទសួរដ៏តប់ប្រមល់ទាំងនេះ ក៏មានអក្សរសិល្ប៍មួយបានលេចឡើងដែលយើងហៅថា *សំណេរអំពីអវសានលោកីយ៍* (ទាក់ទងទៅនឹងការប្រាប់ទុកជាមុននូវព្រឹត្តិការណ៍ដែលពិភពលោកត្រូវបែកបាក់ និង ពេញដោយហិង្សា)។ កណ្ឌគម្ពីរផ្សេងៗទៀតហាក់បីដូចជាត្រូវបានគេអះអាងថា បានសរសេរឡើងដោយតួអង្គពីបុរាណនៅក្នុងព្រះគម្ពីរ។ សេចក្ដីដែលគេហៅថាទំនាយទាំងនេះ បានថ្លែងថាព្រះជាម្ចាស់នឹងបំបែកប្រវត្តិសាស្ត្រនេះ ដោយការវិនិច្ឆ័យ ការដាក់ទោស

យ៉ាងហិង្សា ចំពោះមនុស្សអាក្រក់ ហើយទ្រង់ផ្តល់រង្វាន់ឲ្យមនុស្សសុចរិត។ស្របពេលដែល សំណេរអក្សរសិល្ប៍នេះមានតម្លៃខាងឯប្រវត្តិសាស្ត្រខ្លះ សំណេរនេះ មិនដែលត្រូវបានពួកសាសន៍យូដា និង ក្រុមជំនុំជំនាន់មុនទទួលស្គាល់ថាមានកម្រិតស្មើនឹងបទគម្ពីរនោះទេ។ គំរូមួយនៃអក្សរសិល្ប៍ប្រភេទនេះ គឺសំណេរម្យ៉ាងដែលគេហៅថា *អាប៉ូគ្រីហ្វា(Apocrypha)* ។

ផ្ទុយជាមួយនឹងរឿងទាំងនេះ ព្រះយេស៊ូបានយាងមកដើម្បីបម្រើ សុគត មានព្រះជន្មរស់ឡើងវិញ និង យាងឡើងទៅឯព្រះវរបិតាវិញ។ ទ្រង់បានយាងមកដើម្បីប្រទានក្តីសង្ឃឹម និង ពន្លឺទៅដល់លោកីយ៍ដែលត្រូវបានបាបធ្វើឲ្យទៅជាងងឹត។ ទោះជាយ៉ាងណា ទ្រង់មិនដាក់ទោសមនុស្សអាក្រក់ និង មិនប្រទានរង្វាន់ដល់មនុស្សសុចរិតសោះឡើយ។ ផ្ទុយទៅវិញទ្រង់បាន បង្កើតក្រុមជំនុំ ហើយបង្គាប់ឲ្យអ្នកជឿធ្វើការចែកចាយ ដំណឹងល្អនៅគ្រប់ទីកន្លែង។ ទ្រង់បានមានព្រះបន្ទូល យ៉ាងពិស្តារថា អ្នកដែលដើរតាមទ្រង់ត្រូវបានចែកចាយអ្វីៗទាំងអស់ដែលទ្រង់បានមានព្រះបន្ទូល (គម្ពីរម៉ាថាយ ២៨:២០) ។ ពិតណាស់ យើងក៏ត្រូវការកំណត់ត្រាអំពីអ្វីដែលទ្រង់បានមានព្រះបន្ទូលជាសំណេរខ្លះៗដែរ។

នៅពេលដែលក្រុមជំនុំដំបូងបានរីកលូតលាស់ជាច្រើន ហើយបានពង្រីកទៅដល់គ្រប់ទីកន្លែង អ្នកជឿក៏បានចាស់ទុំឡើងតាមរយៈព័ន្ធកិច្ចនៃការផ្សាយដំណឹងល្អ។ ព័ន្ធកិច្ចនេះ ត្រូវបានចាប់ផ្តើមឡើងដោយអស់អ្នកដែលបានដើរជាមួយព្រះអម្ចាស់ក្នុងអំឡុងពេលទ្រង់គង់នៅលើផែនដី ។ ស្របពេលដែលអ្នកជឿបានរីកលូតលាស់ខាងឯវិញ្ញាណ មានសំណួរជាច្រើនក៏បានលេចឡើងទាក់ទងនឹងការប្រើប្រាស់យ៉ាងពិតជាក់ស្តែងនៃព្រះគុណរបស់ព្រះជាម្ចាស់ទៅជាមួយនឹងបញ្ហាក្នុងជីវិតប្រចាំថ្ងៃ និងទៅជាមួយភាពខុសគ្នាខាងឯវប្បធម៌ ការទាមទារពីសង្គមជុំវិញ និង ទៅជាមួយនឹងអញ្ញទិដ្ឋិ (ផ្នត់គំនិត ឬ គោលលទ្ធិដែលផ្ទុយទៅនឹងជំនឿដែលបានគេទទួលស្គាល់ស្រាប់ហើយ) ។ ពួកគេអ្នកដឹកនាំសាវ័ក បានឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ ដោយសរសេរលិខិតណែនាំ (ហៅថា*គម្ពីរលិខិត)* ដែលត្រូវបានគេចែកចាយបន្តនៅក្នុងចំណោមក្រុមជំនុំ។ ច្បាស់ណាស់ សំណេរទាំងអស់នេះគឺត្រូវបានចាប់ផ្តើមឡើងដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ត្រូវបានទទួលស្គាល់ថាជាបទគម្ពីរដ៏ពិសិដ្ឋ (គម្ពីរ២ពេត្រុស ៣:១៥-១៦) ។ កំណត់ត្រាទាំងនេះត្រូវបានគេហៅថា ដំណឹងល្អ (គម្ពីរម៉ាថាយ គម្ពីរម៉ាកុស គម្ពីរលូកា និង គម្ពីរយ៉ូហាន)។

យើងក៏ត្រូវចាំដែរថា ស្របពេលជាមួយគ្នាដែលក្រុមជំនុំកំពុងពេញវ័យឡើង នឹងមាន "បងប្អូន" ក្លែងក្លាយ "សាវ័ក" ក្លែងក្លាយ និង "ពួកអ្នកប្រឆាំងព្រះគ្រិស្ត" បានចូលខ្លួនមក និង ផ្តល់គោលលទ្ធិរបស់ពួកគេ ឲ្យជ្រៀតចូលមកក្នុងក្រុមជំនុំ។ (សូមអានគម្ពីរ២កូរិនថូស ១១:១២-១៥ គម្ពីរកាឡាទី ១:៦-៩; ៣:១ គម្ពីរកូឡុស ជំពូក២ គម្ពីរ១ធីម៉ូថេ ៤:១-៣ គម្ពីរ២ថេស្សាឡូនិក ជំពូក២ គម្ពីរ២ពេត្រុស ជំពូក២ គម្ពីរ១យ៉ូហាន ២:១៨-១៩ និង គម្ពីរយ៉ូដាស ដែលមាននិយាយអំពីរឿងនេះ)។ ស្របពេលដែលបទគម្ពីរត្រូវបានចែកចាយ នោះក៏មានអក្សរសិល្ប៍ជាច្រើនប្រភេទទៀតក៏ត្រូវបានចែកចាយដែរ។ ដូច្នេះមិនយូរប៉ុន្មានក្រុមជំនុំបានបង្កើតជាមធ្យោបាយមួយក្នុងការបានសំគាល់បទគម្ពីរណាដែលមានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់ ហើយផ្តល់នូវកន្លែងសមរម្យមួយសម្រាប់គម្ពីរនោះនៅក្នុងព្រះវិហារ។ ប្រាកដណាស់ ការធ្វើយ៉ាងដូច្នេះ បានញែកបទគម្ពីរដាច់ដោយឡែកពីសំណេរអក្សរសិល្ប៍ដទៃផ្សេងទៀត។ ច្បាប់ (ឬ បញ្ជី) សម្រាប់បទគម្ពីរសម្ពន្ធមេត្រីថ្មីគឺមានដូចខាងក្រោមនេះ៖

១. បទគម្ពីរនោះត្រូវតែបានសរសេរឡើងដោយ ឬ គាំទ្រដោយសាវ័កមួយរូប។

២. សេចក្តីនៅក្នុងបទគម្ពីរនោះត្រូវ តែនិយាយអំពីតួអង្គខាងឯវិញ្ញាណ ដែលបទគម្ពីរនោះទទួលស្គាល់ថាមានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់មក។

៣. បទគម្ពីរនោះត្រូវតែបានទទួលស្គាល់ជាទូទៅ ដោយក្រុមជំនុំ ថាត្រូវបានបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់។

នៅពេលក្រុមជំនុំចាប់ផ្តើមលេចចេញជារូបរាងដំបូង កណ្ឌគម្ពីរទាំង២៧ នៃគម្ពីរសម្ព័ន្ធមេត្រីថ្មីត្រូវបានវាស់វែងដោយលក្ខណវិនិច្ឆ័យទាំងនេះ ហើយត្រូវបានវិនិច្ឆ័យតាមក្រៅផ្លូវការថាបានបណ្តាល ចិត្តឲ្យតែងពីព្រះជាម្ចាស់។ ការនេះត្រូវបានដាក់ជាផ្លូវការ នៅលើមូលដ្ឋានផ្លូវការ ពេលដែលក្រុមប្រឹក្សានៃក្រុងកាថែត (ក្រុមអ្នកដឹកនាំក្រុមជំនុំមួយក្រុម) បានប្រកាសនៅក្នុងឆ្នាំ ៣៩៧ ថាបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីគឺជាកណ្ឌគម្ពីរទាំង២៧ ដែលត្រូវបានបូករួមនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីសព្វថ្ងៃនេះ។ ដូច្នេះ ក្រុមប្រឹក្សាក្រុមជំនុំបានត្រឹមតែបញ្ជាក់ទៅលើការនេះ នៅពេលក្រោយមកទៀតតែប៉ុណ្ណោះនូវអ្វីដែលអ្នកជឿដែលបានដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធបានទទួលស្គាល់យូរមកហើយ។

## *លំហាត់អនុវត្តន៍*

៩ ចូរប្រាប់ពីកាលបរិច្ឆេទប៉ាន់ប្រមាណ និង ក្រុមដែលទទួលខុសត្រូវក្នុងការរៀបចំពីបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី។

ក) គម្ពីរសម្ព័ន្ធមេត្រីចាស់

ខ) គម្ពីរសម្ព័ន្ធមេត្រីថ្មី

១០ ចូរប្រាប់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់យើង អំពីលក្ខណវិនិច្ឆ័យទាំងបីយ៉ាង សម្រាប់ជ្រើសរើសសំណេររបស់ក្រុមជំនុំដំបូង ដែលត្រូវបូកបញ្ចូលនៅក្នុងបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធថ្មី។ (ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក)។

## ភាពគួរឲ្យទុកចិត្តបាននៃសំណៅដើម(ហត្ថសំណេរ)

ការបណ្តាលចិត្តឲ្យតែងជាពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាអ្វីដែលអ្នកនិពន្ធខិតខំយកមកប្រើជាមួយនឹងសំណេរដំបូង ឬ សំណៅដើម(ហត្ថសំណេរ) នៅពេលដែលពួកគេធ្វើការកត់ត្រាពីការបើកសម្តែងរបស់ព្រះជាម្ចាស់។ យើងមិនមានសំណៅដើមនៃព្រះគម្ពីរទៀតទេ ក្នុងពេលសព្វថ្ងៃនេះ ទោះជាយ៉ាងណា យើងមានច្បាប់ចម្លងល្អៗនៃឯកសារទាំងនោះជាច្រើន ។ ដោយសារតែមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងចំណោមច្បាប់ចម្លងទាំងនោះ យើងមិនអាចនិយាយបានថា ព្រះជាម្ចាស់ទ្រង់បានបណ្តាលចិត្តឲ្យតែងពីទ្រង់ឲ្យមានច្បាប់ចម្លងទាំងអស់នោះឡើយ។

ប៉ុន្តែ ទោះបីជាស្ថិតនៅក្នុងបញ្ហានៃការចម្លង និង ចែកចាយបន្តនូវបទគម្ពីរដ៏ពិសិដ្ឋនេះ ក៏យើងនូវតែឃើញភស្តុតាងជាច្រើនអំពីការការពារ និង ការថែរក្សារបស់ព្រះជាម្ចាស់។ តាមពិតទៅ ការរក្សាទុកនូវសំណេរដ៏សុក្រិត អស់រយៈពេលជាច្រើនជំនាន់នោះហើយ គឺជាការអស្ចារ្យនៃឧបការគុណរបស់ព្រះជាម្ចាស់។ អ្នកផ្ទាល់ក៏ប្រហែលជាអាចនឹងសួរថា៖ "តើសំណេរនោះមានភាពសុក្រិតកម្រិតណាទៅ បើមានភាពខុសគ្នាបន្តិចបន្តួចតែងតែកើតមានឡើងពីច្បាប់ចម្លងមួយទៅច្បាប់ចម្លងមួយទៀតយ៉ាងដូច្នេះ?" ដើម្បីឆ្លើយតបនឹងសំណួរនេះ យើងអាចឆ្លើយយ៉ាងចំៗ និង ប្រកបដោយការអះអាងយ៉ាងច្បាស់ថា៖ "ច្បាប់ចម្លងទាំងនោះគឺពិតជាអាចទុកចិត្តបានមែន! ភាពខុសគ្នាយ៉ាងដូច្នោះ មិនមានឥទ្ធិពលទៅលើជំនឿលើគោលលិទ្ធ ឬសេចក្តីបង្រៀន និង មិនផ្លាស់ប្តូរអ្វីសោះឡើយនៅក្នុងការយល់ដឹងរបស់យើងអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់។

ការពិតគឺថា មានអ្នកជំនាញជាច្រើននាក់ដែលបានចំណាយពេលរាប់សិបឆ្នាំ ធ្វើការប្រៀបធៀបសំណៅដើមចាស់ៗ ជាមួយនឹងគ្នាទៅវិញទៅមក និង ទៅជាមួយនឹងសំណៅដើមដែលគួរឲ្យទុកចិត្តដទៃផ្សេងទៀត។ ពួកអ្នកជំនាញទាំងនោះ បានបន្តការស្រាវជ្រាវបន្ថែមទៀត។ ការរកឃើញថ្មី នៃច្បាប់ចម្លងបុរាណរបស់សំណេរព្រះគម្ពីរ នៅក្បែរសមុទ្រស្លាប់បានបន្ថែមការបញ្ជាក់យ៉ាងអស្ចារ្យទៅលើកិច្ចការនេះ។

លទ្ធផលដែលបានមកពីការសើបអង្កេតរបស់អ្នកប្រាជ្ញនេះ អះអាងប្រាប់យើងថា យើងពិតជាមានសំណេរមួយដែលគួរឲ្យទុកចិត្តពិតមែន។ ការសើបអង្កេតនេះ បង្ហាញថា សំណេរដែលយើងមានសព្វថ្ងៃជាភាសាហេប្រឺ និង ភាសាក្រិកនេះ គឺពិតជាដូចទៅនឹងសំណៅដើម (ហៅថា *សំណេរដើម (* Autographs) ហើយបង្ហាញថាគោលលទ្ធិសំខាន់ទាំងអស់ នៃគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ថ្មី គឺមិនខូចខាតឡើយ។ ព្រះជាម្ចាស់ ដែលបានបណ្តាលចិត្តឲ្យតែង មានការសរសេរអំពីការបើកសម្តែងរបស់ទ្រង់ទៅកាន់មនុស្សជាតិ ទ្រង់បានរក្សាទុកសំណេរនោះជាច្រើនជំនាន់។ យើងអាចទុកចិត្តបានថា ព្រះគម្ពីររបស់យើង គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

នៅពេលដែលព្រះគម្ពីរបានបង្ហាញថា ដើម្បីទទួលបាននូវការបើកសម្តែងពីព្រះជាម្ចាស់ គឺចាំបាច់ទាមទារឲ្យមានការបណ្តាលចិត្តជាពិសេសមួយពីព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរ២ពេត្រុស ១:២០-២១) យើងមិនអាចធ្វើការសន្និដ្ឋានពីព្រះគម្ពីរបានទេ ថាការបណ្តាលចិត្តដូចគ្នានោះ គឺមានសម្រាប់អស់អ្នកដែលបានបកប្រែ ផ្ទេរបន្ត និង ចម្លងបទគម្ពីរដែរនោះទេ។ តាមរបៀបនេះ ខ្ញុំមិនចង់និយាយថា ការបកប្រែគឺមិនអាចទុកចិត្តបាននោះទេ។ ផ្ទុយទៅវិញ យើងដឹងថា ការបកប្រែភាគច្រើនបច្ចុប្បន្ននេះ និង ពីមុន ធ្លាប់តែ និង នៅតែឆ្លងកាត់ការពិនិត្យពិច័យ នៃការសិក្សាយ៉ាងជ្រៅជ្រះ។ ការបកប្រែភាគច្រើន គឺមានគុណភាពខ្ពស់ អស្ចារ្យ។ ទោះជាយ៉ាងណា ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ៗថា យើងមិនអាចយកការបកប្រែណាមួយ មកធ្វើជាសិទ្ធិអំណាចចុងក្រោយ នៅក្នុងជំនឿ និង ការប្រតិបត្តិរបស់យើងនោះឡើយ។ យើងត្រូវតែប្រៀបធៀប ការបកប្រែមួយទៅនិង ការបកប្រែមួយទៀត ព្រមទាំងពិចារណាអំពីភាពត្រឹមត្រូវនៃការបកប្រែនីមួយៗ នៅក្រោមការឆ្លុះបញ្ចាំងពីការសិក្សាយ៉ាងជ្រៅជ្រះ។

## *លំហាត់អនុវត្តន៍*

១១ តើប្រយោគណាខ្លះ នៅខាងក្រោមនេះ ត្រឹមត្រូវ ទាក់ទងនឹងបញ្ជីកណ្ឌគម្ពីរ ដែលបានពិភាក្សានៅក្នុងមេរៀននេះ?

ក) ដោយហេតុតែយើងមិនមានសំណៅដើមនៃបទគម្ពីរ យើងមិនអាចដឹងច្បាស់ថា បញ្ជីកណ្ឌគម្ពីរនោះ គឺជាព្រះបន្ទូលដែលបណ្ដាលចិត្តមកពីព្រះជាម្ចាស់នោះទេ។

ខ) ពាក្យថា *បញ្ជីកណ្ឌគម្ពីរ* បង្ហាញថាកណ្ឌទាំងអស់នៅក្នុងព្រះគម្ពីរ គឺបានស្របតាមខ្នាតគំរូមួយនេះ ៖ គឺថា កណ្ឌគម្ពីរទាំងនោះបានការបណ្ដាលចិត្តពីព្រះជាម្ចាស់។

គ) យើងអាចនឹងទទួលស្គាល់សេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ទាំងទំនុកចិត្ត ព្រោះព្រះជាម្ចាស់មិនត្រឹមតែបានបណ្ដាលចិត្តក្នុងការសរសេរបទគម្ពីរនោះទេ ប៉ុន្តែទ្រង់ក៏បានថែរក្សាបទគម្ពីរអស់រយៈពេលជាច្រើនសតវត្សរ៍មកដែរ។

ឃ) ព្រះជាម្ចាស់មិនត្រឹមតែបានបណ្ដាលចិត្តឲ្យអ្នកនិពន្ធនូវបទគម្ពីរតាមរបៀបពិសេសមួយប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បណ្ដាលចិត្តឲ្យអ្នកប្រាជ្ញដែលធ្វើការបកប្រែអត្ថបទគម្ពីរទៅជាភាសាផ្សេងៗ ដើម្បីឲ្យការបកប្រែទាំងអស់ សុទ្ធតែអាចទុកចិត្តបានទាំងស្រុង។

ង) អក្សរសិល្ប៍អំពីអវសានលោកីយ៍ខ្លះ ដូចជាអក្សរសិល្ប៍ អាប៉ូគ្រីហ្វា (Apocrypha) ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធចាស់ផងដែរ។

ច) គម្ពីរសម្ព័ន្ធមេត្រីចាស់របស់យើង គឺដូចគ្នាទៅនឹងគម្ពីរហេប្រឺដែរ។

ឆ) បញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ មាន៣៩កណ្ឌ ហើយសម្រាប់គម្ពីរសម្ព័ន្ធមេត្រីថ្មីមាន ២៧ កណ្ឌ។

---

# ឃ. ការបកស្រាយបទគម្ពីរ

**វត្ថុបំណងទី៤.** *ប្រាប់អំពីវិធីសាស្ត្រដែលត្រូវដើម្បីវិភាគវែកញែក និង បកប្រែបទគម្ពីរ។*

ប្រហែលជានៅពេលដែលអ្នកអានបទគម្ពីរ អ្នកបានកត់សំគាល់ឃើញថា ខគម្ពីរខ្លះ និង ទិដ្ឋភាពខ្លះនៃបទគម្ពីរ មើលទៅដូចជាមិនបានបង្រៀនច្បាស់ អំពីសកម្មភាព និង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ បទគម្ពីរទាំងនោះ ក៏មិនបានបង្ហាញពីអ្វីដែលទ្រង់បានរំពឹងទុកពីយើងរាល់គ្នាដែរ។ អ្នកអាចនឹង រកមិនឃើញការលើកឡើងអំពីព្រះជាម្ចាស់ផងដែរ។ ខ្ញុំតែងតែឆ្ងល់ណាស់ ឧទាហរណ៍តើកណ្ឌគម្ពីរសាស្ដាអាចនឹងមានតម្លៃអ្វីទៅ ហើយតើហេតុអ្វីបានជាគម្ពីរនេះត្រូវបានរាប់បញ្ចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ មានការលើកឡើងជាច្រើននៅក្នុងគម្ពីរនេះ ដែលផ្ទុយចាកពីសេចក្ដីបង្រៀននៅក្នុងទិដ្ឋភាពដទៃទៀតក្នុងបទគម្ពីរតែម្ដង។ នៅពេលដែលអ្នកអានកណ្ឌគម្ពីរនេះ អ្នកនឹងឃើញថាប្រធានបទ "អ្វីៗទាំងអស់សុទ្ធតែឥតន័យឥតខ្លឹមសារ" (១:២) មានចាក់ស្រេះនៅទូទាំងកណ្ឌគម្ពីរតែម្ដង។

នៅពេលដែលយើងបានអានទៅដល់ខគម្ពីរឬ ទិដ្ឋភាពនៃបទគម្ពីរបែបនេះ យើងត្រូវវិភាគបទគម្ពីរទាំងនោះដោយប្រុងប្រយ័ត្ន ដើម្បីធ្វើការបកស្រាយឲ្យបានត្រឹមត្រូវ។ យើងត្រូវអានអ្វីដែលនៅខាងមុខ និង អ្វីដែលនៅបន្ទាប់ពីខគម្ពីរទាំងនោះ។ នៅក្នុងករណីគម្ពីរសាស្ដានេះ យើងមិនត្រូវកាត់

ផ្ដាច់ប្រយោគទាំងនេះ ចេញពីកណ្ឌគម្ពីរទាំងមូល ឬ ព្រះគម្ពីរទាំងមូល ហើយយកប្រយោគទាំងនោះទៅប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតរបស់យើងនោះឡើយ។ យើងត្រូវអានកណ្ឌគម្ពីរសាស្ដា ទាំងមូល ដើម្បីបានយល់ពីអ្វីទៅជា "ភាពឥតន័យឥតខ្លឹមសារ" នោះ។ នៅពេលដែលយើងអានទៅដល់ជំពូកចុងក្រោយនៃកណ្ឌគម្ពីរនេះ សាររបស់កណ្ឌគម្ពីរទាំងមូលនឹងបានបង្ហាញឲ្យឃើញច្បាស់។ អ្នកនិពន្ធបានចង្អុលបង្ហាញយ៉ាងច្បាស់ៗថា *ពេលដាច់ចេញពីព្រះជាម្ចាស់* ជីវិតគឺពិតជាឥតប្រយោជន៍ និង ឥតន័យឥតខ្លឹមសារឡើយ។ បទពិសោធន៍បានបង្រៀនមេរៀនមួយទៅដល់គាត់ ដែលគាត់ស្វែងរកមធ្យោបាយ ដើម្បី បញ្ជូនបន្តមកកាន់យើងរាល់គ្នា ក្នុងទម្រង់ជាការណែនាំដ៏មានប្រយោជន៍៖

> ក្នុងពេលដែលអ្នកនៅក្មេងនៅឡើយ ត្រូវនឹកដល់ព្រះអាទិកររបស់អ្នក ...... ត្រូវគោរពកោតខ្លាចព្រះជាម្ចាស់ ហើយកាន់តាមបទបញ្ញារបស់ព្រះអង្គ។ នេះហើយជាការដែលមនុស្សគ្រប់ៗរូបត្រូវធ្វើ។ ព្រះជាម្ចាស់នឹងវិនិច្ឆ័យកិច្ចការទាំងប៉ុន្មាន ដែលមនុស្សធ្វើទោះបីជាអំពើដែលគេធ្វើដោយលាក់កំបាំង ហើយជាការល្អ ឬអាក្រក់ក្ដី។ (១២:១, ១៣-១៤)

ឧទាហរណ៍នេះ បង្រៀនយើងពីគោលការណ៍ដ៏មានតម្លៃមួយ៖ គ្រប់ទាំងបទគម្ពីរនីមួយៗ ត្រូវតែធ្វើការវិភាគ និង បកស្រាយនៅក្នុងពន្លឺនៃសេចក្ដីបង្រៀនរបស់ព្រះគម្ពីរទាំងមូល។ ប្រសិនបើយើងរៀន និង ប្រើប្រាស់គោលការណ៍នេះ យើងនឹងកសាងជីវិតជាគ្រិស្តបរិស័ទរបស់យើង នៅលើគ្រឹះដ៏រឹងមាំមួយ។ យើងមិនហ៊ាន យកជីវិតរបស់យើង និង សកម្មភាពរបស់យើងទៅផ្អែកលើខគម្ពីរ ឬ អត្ថបទដកស្រង់ដាច់ដោយឡែកណាមួយឡើយ។ ប្រសិនបើយើងមិនដើរតាមគោលការណ៍នេះទេ យើងអាចមានបង្ហាញធ្ងន់ធ្ងរជាក់ជាមិនខាន។

ព្រះជាម្ចាស់ជួយយើងឲ្យបានយល់សេចក្ដីបង្រៀននៃព្រះបន្ទូលរបស់ទ្រង់។ ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់ មិនត្រឹមតែបានបណ្ដាលចិត្តមនុស្សដែលបានសរសេរបទគម្ពីរប៉ុណ្ណោះទេ តែទ្រង់ក៏*បំភ្លឺ* គំនិតរបស់អស់អ្នកដែលអានបទគម្ពីរនោះផងដែរ។ នេះគឺមានន័យថា ព្រះវិញ្ញាណ*ជះពន្លឺ* នៅក្នុងគំនិតរបស់អ្នកជឿ ឲ្យយល់ពីអ្វីដែលពួកគេអាន។ បើគ្មានជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ គ្មាននរណាម្នាក់អាចយល់បទគម្ពីរត្រឹមត្រូវនោះទេ ព្រោះអំពើបាបបានធ្វើឲ្យគំនិតរបស់ពួកគេខ្មោងងឹតទៅហើយ។ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតនៅក្នុងពួកយើងហើយ ទ្រង់ធ្វើឲ្យយើងដឹងយ៉ាងច្បាស់អំពីសេចក្ដីពិតដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយទ្រង់ជួយយើងឲ្យបកប្រែបទគម្ពីរបានយ៉ាងត្រឹមត្រូវ។ (សូមមើលនៅក្នុងគម្ពីររ៉ូម១:២១ គម្ពីរអេភេសូ ១:១៨; ៤:១៨ គម្ពីរ១កូរិនថូស ២:៦-១៦ និង គម្ពីរ១យ៉ូហាន២:២០,២៧)។

បន្ទាប់មក យើងឃើញថាព្រះគម្ពីរគឺជាការបើកសម្ដែងរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សជាតិ។ ស្របពេលដែលការលើកឡើងខ្លះ ដែលមានកត់ត្រានៅក្នុងព្រះគម្ពីរមើលទៅហាក់បីដូចជាមានភាពផ្ទុយគ្នាក៏ដោយ តែនៅពេលដែលធ្វើការបកស្រាយនៅក្នុងពន្លឺនៃព្រះគម្ពីរទាំងមូល ការលើកឡើងទាំងអស់នោះនឹងមានន័យច្បាស់លាស់។ លើសពីនេះទៅទៀត ព្រះវិញ្ញាណដ៏វិសុទ្ធទ្រង់បានបំភ្លឺគំនិតរបស់យើង ដើម្បីឲ្យយើងអាចបកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់បានយ៉ាងត្រឹមត្រូវ ហើយព្រមទាំងយល់អំពីមេរៀនដែលទ្រង់សព្វព្រះទ័យបង្រៀនយើង។

## *លំហាត់អនុវត្តន៍*

១២ ចូរបំពេញប្រយោគ៖ បទគម្ពីរនីមួយៗត្រូវតែទទួលការវិភាគ និង បកស្រាយនៅក្នុងពន្លឺ និង សេចក្តីបង្រៀននៃ........................................................................................................

# ខ. សិទ្ធិអំណាចរបស់បទគម្ពីរ

**វត្ថុបំណងទី៥.** *ប្រាប់ថាតើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គួរតែមានអំណាចនៅក្នុងត្រង់កន្លែងណាក្នុងជីវិតរបស់យើង។*

សំណួរដ៏មានសារៈសំខាន់មួយបានលេចឡើង នៅពេលយើងសិក្សាព្រះគម្ពីរ។ តើមានសារៈសំខាន់ប្រភេទណា ដែលអ្នកនឹងផ្តល់ទៅកាន់ព្រះគម្ពីរ បើគិតទាក់ទងនឹងជីវិត និង ឆន្ទៈរបស់យើង? បទគម្ពីរបានបង្ហាញតាំងពីដំបូងរហូត ដល់ចុងបញ្ចប់ អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងបញ្ហាមួយនេះ។ យើងដឹងថាបទគម្ពីរគឺ ត្រូវតែជាសិទ្ធិអំណាចចុងក្រោយបង្អស់ នៅក្នុងបញ្ហាខាងឯជំនឿ និង ការប្រតិបត្តិ (គម្ពីរ ២ធីម៉ូថេ ៣:១៦-១៧)។

កាលពីដើមឡើយ នៅក្នុងការទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយមនុស្ស ព្រះជាម្ចាស់ទ្រង់បានបង្ហាញ បំណងព្រះហឫទ័យ និង គោលបំណងរបស់ទ្រង់។ ទ្រង់ក៏អនុញ្ញាតឲ្យមនុស្សរបស់ទ្រង់ ដឹងថាទ្រង់បានរំពឹងឲ្យពួកគេស្គាល់ ក្រឹត្យវិន័យរបស់ទ្រង់ និង អនុវត្តទៅតាមក្រឹត្យវិន័យនោះ ៖ "ចំណែកឯអ្នករាល់គ្នាវិញ ត្រូវកាន់ និងប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នា ដោយឥតបន្ថែម ឬបន្ថយអ្វីឡើយ (គម្ពីរទុតិយកថា ១២:៣២) ។ ទ្រង់ថែមទាំងបានមានព្រះបន្ទូល ថាទ្រង់អាចនឹងល្បងលពួកគេដើម្បីឃើញថា តើពួកគេយល់ពីព្រះបន្ទូលរបស់ទ្រង់ ហើយធ្វើតាមព្រះបន្ទូលនោះដែរឬទេ (គម្ពីរទុតិយកថា ១៣:៣)។

ចុះប្រសិនបើមានព្យាការី ឬ អ្នកបកស្រាយសុបិន្តម្នាក់បានអញ្ជើញមកក្នុងតំបន់របស់អ្នក ព្រមទាំងបានធ្វើការអស្ចារ្យ ឬ បំពេញតាមសេចក្តីសន្យាតាមរបៀបពិសេសអស្ចារ្យមួយ។ តើការនោះនឹងអាចធ្វើឲ្យគាត់ ក្លាយជាព្យាការីដ៏ពិតម្នាក់ដែរឬទេ? មិនអាចទេ លុះត្រាតែអ្វីដែលបុគ្គលនោះនិយាយ គឺយោងទៅតាមអ្វីដែលព្រះជាម្ចាស់បានបង្រៀន នៅក្នុងព្រះបន្ទូលរួចមកហើយ (សូមមើល គម្ពីរទុតិយកថា ១៣:១-៣)។

គោលការណ៍នេះ គឺត្រូវបានលើកយកមកនិយាយម្តងហើយម្តងទៀត នៅពាសពេញបទគម្ពីរទាំងមូលតែម្តង។ យើងមិនត្រូវធ្វើឲ្យវង្វេង ដោយសារតែអច្ឆរិយវត្ថុ ទីសំគាល់ ការអស្ចារ្យ ដែលទាំងនេះគឺគ្រាន់តែជាការកំសាន្ត ឬ អ្វីដែលទាញយើងចេញពីសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះឡើយ។

មធ្យោបាយសម្រាប់យើងដើម្បីបន្តទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវគឺការរស់នៅតាមព្រះបន្ទូលរបស់ទ្រង់ ៖ « បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិរបស់ខ្ញុំ នោះអ្នកនឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ » ( យ៉ូហាន ១៥:១០ ) ។ យើងអាចបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រិស្ត ដោយការគោរពតាមព្រះហឫទ័យរបស់ទ្រង់ដែលបានបើកសម្តែង៖ « បើអ្នកធ្វើតាមសេចក្តីដែលខ្ញុំបង្គាប់អ្នករាល់គ្នាជាមិត្តសម្លាញ់របស់ខ្ញុំហើយ» (យ៉ូហាន ១៥:១៤)។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាសេចក្តីពិត (គម្ពីរយ៉ូហាន ១៧:១៧)។ ដូច្នេះហើយ យើងត្រូវធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្លាយទៅជាសិទ្ធិអំណាចខ្ពស់ជាងគេនៅក្នុងជីវិតផ្ទាល់ខ្លួន និង ជីវិតរួមក្រុមជំនុំរបស់អ្នក។ នៅក្នុងអគារព្រះវិហាររបស់យើងជាច្រើន យើងបានដាក់វេទិកាចំណុចកណ្តាលនៃប្លង់ ព្រោះតែកន្លែងនោះជាកន្លែងដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានចែកចាយ។ ការនេះបង្ហាញឲ្យឃើញពីអ្វីដែលអ្នកនិពន្ធ ដាវីឌ បានមានប្រសាសន៍ថា៖ "ដ្បិតទ្រង់បានដំកើងព្រះបន្ទូលទ្រង់ឲ្យធំលើសព្រះនាមទ្រង់ទៅទៀត" (គម្ពីរទំនុកតម្កើង ១៣៨:២ គម្ពីរ ពគប)។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺត្រូវដើរមុន គ្រប់ទិដ្ឋភាពនៅក្នុងជីវិតរបស់យើង។ យើងត្រូវបានដាក់សេចក្តីបង្រៀនរបស់ព្រះបន្ទូល នៅលើអ្វីដែលជារបស់គ្រួសារ និង មិត្តភក្តិ។ យើងត្រូវបានផ្តោតការយកចិត្តទុកដាក់ ទៅលើការព្រមាន និង ការដឹកនាំរបស់ព្រះបន្ទូល។ ព្រះបន្ទូលត្រូវតែគ្រប់គ្រងលើអារម្មណ៍របស់យើង។

ដូច្នេះ តើការដែលមានសេចក្តីបង្រៀនព្រះគម្ពីរដ៏រឹងមាំនៅក្នុងក្រុមជំនុំរបស់យើងនោះ មានសារៈសំខាន់យ៉ាងណាទៅ? យើងត្រូវជំរុញឲ្យមានសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តរបស់អ្នកជឿ ទៅចំពោះសិក្សាជាលក្ខណៈប្រព័ន្ធ អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មនុស្សម្នាគួរតែចូលមករួមគ្នា នៅក្នុងដំណាក់របស់ព្រះជាម្ចាស់ មិនគ្រាន់តែសម្រាប់កម្មវិធី ឬ រឿងបុគ្គលណានោះទេ ប៉ុន្តែដោយសារពួកគេស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។

> ស្មៅតែងតែក្រៀម ហើយផ្កាក៏ស្រពោន ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះនៃយើង នៅស្ថិតស្ថេរអស់កល្បជានិច្ច។ (គម្ពីរអេសាយ ៤០:៨)

## លំហាត់អនុវត្តន៍

១៣ ដោយយោងទៅតាមអ្វីដែលយើង បានរៀននៅក្នុងចំណុចនេះ ចូរបកស្រាយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ថាតើសិទ្ធិអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺតែងមានកន្លែងនៅត្រង់ណាក្នុងជីវិតរបស់យើង។

# ការប្រឡងផ្ទាល់ខ្លួន

## ផ្គូផ្គង។

១ ចូរផ្គូផ្គងពាក្យនីមួយៗ (ខាងស្តាំ) ទៅជាមួយនឹងនិយមន័យរបស់វា (ខាងឆ្វេង)។

.........ក) ការបញ្ជូនបន្តរឿងរ៉ាវ ដែលមិនមែនជាសំណេរ ពីជំនាន់មួយទៅជំនាន់មួយទៀត។

.........ខ) អ្វីដែលកើតមានឡើងនៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងឲ្យបានយល់ពីបទគម្ពីរ

.........គ) ជាសំណេរដើមដំបូងបង្អស់នៃបទគម្ពីរ

.........ឃ) ជាសកម្មភាពពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធក្នុងការដឹកនាំអ្នកនិពន្ធដែលបានសរសេរកណ្ឌនៃព្រះគម្ពីរ។

.........ង) ការលាតត្រដាងអំពីព្រះជាម្ចាស់ដោយអង្គទ្រង់ផ្ទាល់ និង សកម្មភាពរបស់ទ្រង់ ដែលពីមុនមកគ្មាននរណាម្នាក់បានដឹង

..........ច) ជាសំណេរដែលមានលក្ខណៈជាការប្រកាសទុកមុននូវព្រឹត្តិការណ៍ដ៏ហិង្សា និង ការបែកបាក់នៃលោកីយ៍

.........ឆ) ប្រព័ន្ធនៃរង្វាស់ដែលផ្អែកទៅលើលក្ខណវិនិច្ឆ័យជាក់លាក់ណាមួយ ដើម្បីកំណត់ថាបញ្ជីកណ្ឌគម្ពីរណាដែលត្រូវបានបណ្ដាលចិត្តពីព្រះជាម្ចាស់។

១) អក្សរសិល្ប៍អវសានលោកីយ៍
២) សំណេរដើម
៣) ប្រពៃណីនិយាយតៗគ្នា
៤) បញ្ជីកណ្ឌគម្ពីរ
៥) ការបណ្ដាលចិត្តឲ្យតែង
៦) ការបំភ្លឺ
៧) ការបើកសម្ដែង

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅខាងមុខប្រយោគដែលមិនត្រឹមត្រូវ។

........២ ក្រុមជំនុំគឺជាសិទ្ធិអំណាចចុងក្រោយបង្អស់ នៅក្នុងបញ្ហា ជំនឿ និង ការប្រតិបត្តិ។

........៣ ដើម្បីយល់ពីសេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងត្រូវតែធ្វើការវិភាគ និង បកស្រាយយ៉ាងប្រុងប្រយ័ត្ន ចំពោះអ្វីដែលបានសរសេរនៅក្នុងពន្លឺនៃសេចក្ដីបង្រៀនដែលមាននៅក្នុងព្រះគម្ពីរទាំងមូល។

.........៤ ការបណ្ដាលចិត្តឲ្យតែងសម្រាប់បទគម្ពីររួមមាន សំណេរដើម ច្បាប់ចម្លងនៃសំណេរដើម ការបកប្រែ និង កំណែថ្មីផ្សេងៗ។

........៥ យើងមានការអះអាងបញ្ជាក់ថាព្រះគម្ពីររបស់យើងគឺពិតជាអាចទុកចិត្តបានថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រោះយើងឃើញពីភស្តុតាងដែលព្រះជាម្ចាស់បានរក្សាទុកសំណេរយ៉ាងសុក្រឹត ឆ្លងកាត់ជាច្រើនជំនាន់។

.........៦ គ្រប់កណ្ឌគម្ពីរទាំងអស់ ដែលត្រូវបានទទួលស្គាល់នៅក្នុង បញ្ជីកណ្ឌគម្ពីរ គឺត្រូវបានគេទទួលស្គាល់ថាជាការបណ្តាលចិត្តឲ្យតែងមកពីព្រះជាម្ចាស់។

........៧ *ភាពផ្តាច់មុខ* នៃបទគម្ពីរមានន័យថា នៅក្នុងកណ្ឌគម្ពីរទាំង៦៦កណ្ឌ យើងទទួលបានការបើកសម្តែងជាការសរសេរយ៉ាងពេញលេញរបស់ព្រះជាម្ចាស់។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៧ ក) គម្ពីរយ៉ូហាន ១៦:១២-១៥

ខ) ការដឹកនាំ និង ការបំភ្លឺផ្លូវរបស់ព្យាការី និង សេចក្តីបង្រៀនបន្ថែមទៀត។

គ) គម្ពីរអេភេសូ ៣:៤-៥, ៩-១០ គម្ពីរ២ពេត្រុស ៣:១៥-១៦ គម្ពីរ២ពេត្រុស ១:២០-២១

១ ការបើកសម្តែងទាក់ទងនឹងព្រះជាម្ចាស់ មានន័យថា ព្រះជាម្ចាស់បានបង្ហាញទៅកាន់មនុស្ស អំពីអ្វីដែលពួកគេមិនអាចដឹងដោយខ្លួនឯង អំពីទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់។

៨ ព្រោះយើងនឹងដឹងថា យើងត្រូវច្រានចោលការបើកសម្តែងទាំងឡាយណាដែលមកតាមក្រោយ ដោយការបើកសម្តែងទាំងនោះ មិនស្របទៅតាមអ្វីដែលព្រះជាម្ចាស់បានបង្ហាញរួចមកហើយនោះទេ ហើយការបើកសម្តែងទាំងនោះក៏មិនថ្វាយសិរីរុងរឿងដល់ទ្រង់ដែរ។

២ ក) និង ឃ) គឺជាចម្លើយត្រឹមត្រូវ។

៩ ក) ប្រហែលឆ្នាំ៥០០ មុនគ.ស ដោយលោកអែសរ៉ា និង សមាជិកនៅក្នុងមហាសាលាប្រជុំ។

ខ) ឆ្នាំ៣៩៧ គ.ស ដោយក្រុមប្រឹក្សា ក្រុងកាថែត។

៣ ក) "ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរកត់ត្រាព្រឹត្តិការណ៍នេះក្នុងក្រាំងមួយ ...."

ខ) "លោកម៉ូសេបានកត់ត្រាទុកនូវព្រះបន្ទូលទាំងប៉ុន្មានរបស់ព្រះអម្ចាស់។"

គ) "ទ្រង់មានព្រះបន្ទូលថា" (លោកអេសាយគឺជាអ្នកសរសេរ)

ឃ) "ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈលោកយេរេមាដូចតទៅ"

ង) "ព្រះអម្ចាស់មានព្រះបន្ទូលថា"

ច) "ប្រសិនបើនរណាម្នាក់នឹកស្មានថា ខ្លួនជាអ្នកថ្លែងព្រះបន្ទូល ឬស្មានថា ខ្លួនជាអ្នកទទួលអំណោយទានពីព្រះវិញ្ញាណ ត្រូវអោយអ្នកនោះទទួលស្គាល់ថា សេចក្តីដែលខ្ញុំសរសេរជូនមកបងប្អូននេះ ក៏ជាបទបញ្ជារបស់ព្រះអម្ចាស់ដែរ"

ឆ) "លោកប៉ូលជាបងប្អូនដ៏ជាទីស្រឡាញ់របស់យើង បានសរសេរមកជូនបងប្អូន តាមប្រាជ្ញាដែលព្រះជាម្ចាស់ប្រទានអោយលោកស្រាប់ហើយ។" (សូមសំគាល់មើល ខ១៦ ដែលលោកពេត្រុសទទួលស្គាល់អ្វីដែលលោកប៉ូលបានសរសេរ ថាជាបទគម្ពីរ។)

១០ សំណេរទាំងនោះត្រូវតែសរសេរឡើង ឬ គាំទ្រដោយសាវ័កមួយរូប។ ខ្លឹមសារនៅក្នុងសំណេរនោះត្រូវតែមានលក្ខណខាងឯវិញ្ញាណ ដែលបង្ហាញថាសំណេរគឺពិតជាទទួលបានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់មែន។ សំណេរនោះត្រូវតែបានទទួលស្គាល់ដោយក្រុមជំនុំទាំងមូល ថាជាការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់។

៤ ខ) ការផ្តល់សិទ្ធិអំណាច ជាក់លាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់កិច្ចការដ៏ជាក់លាក់មួយ

ឃ) ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅលើមនុស្សដែលត្រូវបានជ្រើសតាំងឲ្យកត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់ ទាក់ទងនឹងអង្គទ្រង់ផ្ទាល់ ព្រមទាំងផែនការរបស់ទ្រង់ផងដែរ។

ច) ខ្លឹមសារ ទាំងអស់នៃបទគម្ពីរ រួមទាំងធាតុផ្សំដែលត្រូវបានជ្រើសរើសយកមកដាក់បញ្ចូល និង ពាក្យពេចន៍ដែលត្រូវបានជ្រើសរើស។

១១ ខ), គ),ច) និង ឆ) ជាចម្លើយត្រឹមត្រូវ។

៥ ទោះបីជាតាមវប្បធម៌ ត្រូវតែបំបាក់ឆ្អឹងដើម្បីពន្លឿនការស្លាប់របស់អ្នកដែលត្រូវគេឆ្កាងក៏ដោយ តែគេមិនចាំបាច់បំបាក់ឆ្អឹងរបស់ព្រះយេស៊ូឡើយ ព្រោះពួកទាហានបានឃើញថាទ្រង់បានសុគតរួចទៅហើយ ដូច្នេះផ្ទុយទៅវិញ ពួកគេបានចាក់ទម្លុះឆ្អឹងជំនីម្ខាងរបស់ទ្រង់ជាមួយនឹងលំពែងវិញ

១២ ព្រះគម្ពីរទាំងមូល ឬ ទាំងស្រុង។

៦ ក) ព្រះយេស៊ូបានបង្ហាញការគោរព និង ទទួលស្គាល់បទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ បទទំនាយនៅក្នុងព្រះគម្ពីរជាច្រើន ត្រូវបំពេញរួចទៅហើយ។ មានការរួបរួមមួយនៅក្នុងសាច់រឿងក្នុងព្រះគម្ពីរ។

ខ) ទ្រង់បានដកស្រង់យកបទគម្ពីរមកមានព្រះបន្ទូលជារឿយៗ។

គ) ឧទាហរណ៍មួយគឺ កន្លែងដែលព្រះយេស៊ូប្រសូត ដែលត្រូវបានប្រាប់ទុកជាមុនដោយ ព្យាការីមីកា ។ មួយទៀតគឺរបៀបដែលទ្រង់សុគត ត្រូវបានប្រាប់ទុកជាមុនដោយ ព្យាការីអេសាយ និង លោកដាវីឌ។

ឃ) ការប្រោសលោះមនុស្សជាតិ។

១៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយដូចតទៅនេះ៖ ព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់គួរតែជាសិទ្ធិអំណាចចុងក្រោយរបស់យើងនៅក្នុង បញ្ហានៃជំនឿ (ការជឿ)របស់យើង និង ការប្រតិបត្តិរបស់យើង។ ព្រះគម្ពីរគួរតែបានដឹកនាំទង្វើ គំនិត និង អារម្មណ៍របស់យើង។ យើងត្រូវសិក្សាព្រះគម្ពីរ ដោយចិត្តស្មោះត្រង់ និង យកសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទៅដាក់ក្នុងជីវិតរបស់យើងទាំងស្រុង។